**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
**Université Royale de Droit et des Sciences Economiques**
**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# នីតិវិធីនៃការចុះបញ្ជីក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូន ផ្លូវគោកតាមប្រព័ន្ធស្វ័យប្រវត្តិកម្មនៅកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨

តាក់តែងឡើងដោយ
និស្សិតឈ្មោះ **គីមលី ករុណា**
**វ៉ាន សុវណ្ណឌី**

សាស្ត្រាចារ្យណែនាំ
លោក **ស៊ិន សន្ធា**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**
ជំនាន់ទី ១១

ឆ្នាំចូលសិក្សា ២០១៤
ឆ្នាំសរសេរសារណា ២០១៨

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីររូបឈ្មោះ **គីមលី ករុណា** និង **ម៉ាន សុវណ្ណឌី** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែករដ្ឋបាលសាធារណៈ ជំនាន់ទី១១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។

សូមធ្វើគារវកិច្ចសម្តែងនូវកតញ្ញូតាធម៌ចំពោះ លោកអ្នកមានគុណទាំងពីរ ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា ផ្តល់ដំបូន្មានល្អៗដល់រូបកូនឱ្យដើរតាមគន្លងធម៌ និងបញ្ជូនកូនឱ្យចូលរៀន តាំងពីបឋមសិក្សារហូតដល់ថ្នាក់បរិញ្ញាបត្រ ថែមទាំងជ្រោមជ្រែងកូនសព្វបែបយ៉ាង ទាំងស្មារតី ធនធាន និងសម្ភារៈ។ គុណលោកទាំងពីរ ពុំមានអ្វីអាចយកមកប្រៀបផ្ទឹមបាននោះទេ គឺមកពីគុណបំណាច់ដ៏ធំធេងនេះហើយ ទើបជំរុញឱ្យជីវិតកូនទទួលបានជោគជ័យរហូតដល់សព្វថ្ងៃនេះ។

យើងខ្ញុំសូមថ្លែងអំណរគុណផងដែរចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ** សាកលវិទ្យាធិការរង ព្រឹទ្ធបុរស និងលោកគ្រូ អ្នកគ្រូជាសាស្រ្តាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានដឹកនាំសម្របសម្រួលបង្ហាត់បង្រៀនយ៉ាងយកចិត្តទុកដាក់ និងចំណាយពេលវេលាដ៏មានតម្លៃក្នុងការតម្រង់ទិស និងចែករំលែកចំណេះដឹងល្អៗ ព្រមទាំងបទពិសោធន៍ថ្មីៗ ដើម្បីបំពេញវិជ្ជាដល់យើងខ្ញុំទាំងអស់គ្នា តាំងពីថ្នាក់មូលដ្ឋានរហូតដល់ថ្នាក់បញ្ចប់។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតដល់ លោកសាស្រ្តាចារ្យណែនាំ **ស៊ិន សទ្ធា** ដែលបានជួយពន្យល់ណែនាំ ក្នុងការសរសេរសារណាបញ្ចប់ការសិក្សានេះ ដោយលោកបានចំណាយពេលវេលាដ៏មានតម្លៃ ទាំងកម្លាំងកាយ កម្លាំងចិត្ត ទាំងការផ្តល់គំនិត ដោយមិនខ្លាចនឿយហត់ ដើម្បីឱ្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រយើងខ្ញុំលេចចេញជារូបរាងយ៉ាងល្អប្រសើរ។

យើងខ្ញុំសូមថ្លែងអំណរគុណដល់ **លោក ខ្លាំខ សុខា** អនុប្រធាននាយកដ្ឋាននៃនាយកដ្ឋានពត៌មានវិទ្យា និងទំនាក់ទំនងសាធារណៈ និង **លោក ឡេខ វណ្ណថា** ប្រធានការិយាល័យអាជីវកម្មដឹកជញ្ជូនក្នុងប្រទេស និងឆ្លងដែនតាមផ្លូវគោកនៃនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក ព្រមទាំងមន្ត្រីទាំងអស់របស់នាយកដ្ឋានទាំងពីរ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីពន្យល់ណែនាំរាល់ចម្ងល់ និងផ្តល់នូវឯកសារដែលពាក់ព័ន្ធ ព្រមទាំងជួយកែប្រែរាល់កំហុសឆ្គងថែមទៀត ដែលការជួយជ្រោមជ្រែងទាំងនេះជំរុញឱ្យយើងខ្ញុំខិតខំបន្តការស្រាវជ្រាវនេះរហូតបានសម្រេច។

ជាទីបញ្ចប់ យើងខ្ញុំសូមគោរពជូនពរ លោកអ្នកមានគុណទាំងពីរ និងអស់លោកអ្នកដែលបានរៀបរាប់ខាងលើឱ្យជួបប្រទះតែនឹងសេចក្តីសុខ សេចក្តីចម្រើន និងពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ ជានិរន្តរ៍តរៀងទៅកុំបីអាក់ខានឡើយ។

# អារម្ភកថា

ដើម្បីជាការរួមចំណែកដល់ការស្រាវជ្រាវក្រោយៗទៀត និងបំពេញតាមលក្ខខណ្ឌនៃការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែករដ្ឋបាលសាធារណៈ យើងខ្ញុំទាំងពីររូបជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែករដ្ឋបាលសាធារណៈ ជំនាន់ទី១១ ក្រុមP4C2 ឆ្នាំសិក្សា២០១៧-២០១៨ មានសេចក្តីសោមនស្សរីករាយ និងមោទនភាពយ៉ាងខ្លាំង ដោយបានខិតខំព្យាយាមចងក្រងអត្ថបទសារណាស្តីពី « នីតិវិធីនៃការចុះបញ្ជីក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកតាមប្រព័ន្ធស្វ័យប្រវត្តិកម្មនៅកម្ពុជា » ។

យើងខ្ញុំទាំងពីររូបសង្ឃឹមយ៉ាងមុតមាំថា សារណានេះគឺជាមូលដ្ឋាននៃចំណេះដឹងមួយផ្នែកយ៉ាងធំ ដើម្បីទទួលបានការយល់ដឹងអំពីនីតិវិធីនៃការចុះបញ្ជីក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ដែលមានទាំងផលវិជ្ជមាន និងអវិជ្ជមាន ក្នុងពេលអនុវត្តន៍កន្លងមក និងពេលអនាគត ដែលអាចឈានទៅរកការវិវត្តឱ្យកាន់តែប្រសើរឡើង និងប្រកបដោយចីរភាព។ ទោះជាយ៉ាងណាក៏ដោយ សារណានេះមិនអាចគ្របដណ្តប់គ្រប់ទិដ្ឋភាពអនុវត្តន៍ពិស្តារ ហើយក៏អាចនឹងមានកំហុសដោយអចេតនា និងកំហុសបច្ចេកទេសមួយចំនួនផងដែរ។

ដោយមានការខិតខំប្រឹងប្រែងយ៉ាងអត់ធ្មត់ និងយកចិត្តទុកដាក់បំផុតក្នុងការប្រមូលចំណេះដឹងដែលបានសិក្សាអស់រយៈ៤ឆ្នាំកន្លងមក គួបផ្សំជាមួយការស្រាវជ្រាវឯកសារជាច្រើនបន្ថែមទៀតនោះ ធ្វើឱ្យសារណារបស់យើងខ្ញុំទាំងពីររូបលេចចេញនូវរូបរាង ថែមទាំងទទួលបានលទ្ធផលជាទីគាប់ចិត្ត។

ជាចុងក្រោយនេះ យើងខ្ញុំទាំងពីររូបមានក្តីបេតិសោមនស្សរីករាយជាទីបំផុត ក្នុងការរង់ចាំទទួលនូវមតិរិះគន់នូវរាល់កំហុសឆ្គងទាំងឡាយ ក្នុងន័យស្ថាបនាពីសំណាក់លោកសាស្ត្រាចារ្យ បញ្ញាវន្ត និស្សិត និងមិត្តអ្នកអានទាំងអស់ ដើម្បីយកមកកែលម្អឱ្យកាន់តែមានភាពប្រសើរឡើងជាងនេះ។

# មាតិកា

ទំព័រ


**តារាងសម្គាល់អក្សរកាត់**......iii

**សេចក្ដីផ្ដើម** ...... **១**

១. លំនាំបញ្ហានៃការស្រាវជ្រាវ......១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ...... ២

៣. គោលបំណងនៃការស្រាវជ្រាវ ...... ២

៤. ដែនកំណត់នៃការស្រាវជ្រាវ ...... ៣

៥. សារៈសំខាន់នៃការស្រាវជ្រាវ......៣

៦. វិធីសាស្ត្រនៃការស្រាវជ្រាវ......៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ......៤

**ជំពូកទី ១ សញ្ញាណទូទៅនៃប្រព័ន្ធស្វ័យប្រវត្តិកម្ម**

១.១ អ្វីទៅជាប្រព័ន្ធស្វ័យប្រវត្តិកម្ម?......៦

១.២ អត្ថប្រយោជន៍នៃប្រព័ន្ធស្វ័យប្រវត្តិកម្ម......៦

១.៣ ទិដ្ឋភាពទូទៅនៃការអនុវត្តប្រព័ន្ធស្វ័យប្រវត្តិកម្មក្នុងវិស័យសេវាសាធារណៈមួយចំនួននៅប្រទេសកម្ពុជា ......៦

១.៤ ទិដ្ឋភាពទូទៅនៃការអនុវត្តប្រព័ន្ធស្វ័យប្រវត្តិកម្មក្នុងវិស័យដឹកជញ្ជូនផ្លូវគោក ......៨

១.៥ ទិដ្ឋភាពទូទៅនៃការចុះបញ្ជីក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសតាមប្រព័ន្ធស្វ័យប្រវត្តិកម្មនៅក្រសួងសាធារណការ និងដឹកជញ្ជូន ......១០

**ជំពូកទី ២ នីតិវិធីនៃការចុះបញ្ជីក្រុមហ៊ុន**

**អាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម**

២.១ ដំណាក់កាលសំខាន់ៗនៃនីតិវិធីក្នុងការចុះបញ្ជីក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម......១៣

២.១.១ ដំណាក់កាលអ្នកដាក់ពាក្យស្នើសុំ( នីតិបុគ្គល ឬតំណាងស្របច្បាប់) ...... ១៣
២.១.១.១ ដំណាក់កាលប្រមូលឯកសារពាក់ព័ន្ធ ...... ១៣
២.១.១.១.១ លក្ខខណ្ឌ ...... ១៣
២.១.១.១.២ ការប្រមូលឯកសារ ...... ១៣
២.១.១.២ ដំណាក់កាលអនុវត្តលើប្រព័ន្ធស្វ័យប្រវត្តិកម្ម ...... ១៥
២.១.១.២.១ ការបង្កើតគណនី ...... ១៥
២.១.១.២.២ ការចូលប្រើប្រាស់ ...... ១៦
២.១.១.២.៣ ការបង់កម្រៃសេវាសាធារណៈ ...... ១៧
២.១.២ ដំណាក់កាលមន្ត្រីផ្តល់សេវា ...... ១៨
២.១.៣ ដំណាក់កាលរវាងមន្ត្រីផ្តល់សេវា និងអ្នកដាក់ពាក្យស្នើសុំ ...... ១៩
**២.២ កាតព្វកិច្ចក្រោយការប្រគល់វិញ្ញាបនបត្រ ...... ២០**
២.២.១ អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក ...... ២០
២.២.២ ក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស ...... ២០
**២.៣ ការបាត់បង់សុពលភាពមុនពេលកំណត់ ...... ២១**

**ជំពូកទី ៣ ការពិភាក្សាលើនីតិវិធីនៃការចុះបញ្ជី**
**ក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម**

**៣.១ ចំណុចខ្លាំង ...... ២២**
**៣.២ ចំណុចខ្សោយ ...... ២៥**
**៣.៣ បញ្ហាប្រឈម ...... ២៦**
**៣.៤ ដំណោះស្រាយ ...... ២៧**
**៣.៥ កាលានុវត្តភាព ...... ២៩**
**សេចក្តីសន្និដ្ឋាន ...... ៣១**
**អនុសាសន៍ ...... ៣៣**
**ឯកសារយោង**
**បញ្ជីឧបសម្ព័ន្ធ**

# តារាងសម្គាល់អក្សរកាត់

- CMVIC : Cambodia Motor Vehicle Inspection Company
- ICT : Information and Communication Technology
- JICA : Japan International Cooperation Agency
- App : Application
- QR Code : Quick Response Code
- E-Government : Electronic Government ,e-gov, Digital Government, Online Government, Transformational Government
- MPWT : Ministry of Public Works and Transport

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

មនុស្សលោកយើងរស់នៅសព្វថ្ងៃលើភពផែនដីនេះពឹងផ្អែកលើកត្តាផ្សេងៗជាចំបាច់ ក្នុងការរស់នៅ ទំនាក់ទំនង និងការប្រកបរបរអាជីវកម្ម។ មនុស្សរស់នៅពឹងផ្អែកខ្លាំងលើលុយកាក់ អាហារ ទីជម្រក សម្លៀកបំពាក់ ទំនាក់ទំនងក្នុងសង្គមជាដើម។ ប៉ុន្តែទាំងអស់នេះមិនគ្រប់គ្រាន់សម្រាប់ការរស់នៅរបស់សង្គមមនុស្សលោកនាសតវត្សទី២១នោះទេ។ មនុស្សត្រូវការអ្វីមួយដែលថ្មីប្លែក ងាយស្រួល និងរហ័សទាន់ចិត្តនោះគឺ ការវិវត្តនៃបច្ចេកវិទ្យាថ្មីៗ។ បច្ចេកវិទ្យា (Technology) ជាចំណេះដឹងវិទ្យាសាស្ត្រមួយដែលគេប្រើប្រាស់វាក្នុងវិស័យ និងមុខងារនានា រួមមាន វិស័យពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម សុខាភិបាល រដ្ឋបាល អាជីវកម្ម ឬជាមួយនឹងឧបករណ៍អេឡិចត្រូនិចផ្សេងៗ ជាអាទិ៍។ បន្ថែមពីនេះទៀត ស្របជាមួយនឹងសាកលភាវូបនីយកម្ម បច្ចេកវិទ្យាបាននឹងកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញឱ្យមានការអភិវឌ្ឍរបស់ពិភពលោក។ នាពេលបច្ចុប្បន្ននេះ បច្ចេកវិទ្យាបានជួយសង្គមមនុស្សយ៉ាងធំធេងទាំងក្នុងការរស់នៅ ទំនាក់ទំនង ការងារ ការសិក្សាស្រាវជ្រាវ ដែលផ្តល់នូវសក្តានុពលភាពនៃការវិវត្តយ៉ាងលឿននៃរបត់សាកលភាវូបនីយកម្ម។

បើងាកមកមើលក្នុងព្រះរាជាណាចក្រកម្ពុជាវិញ យើងពិនិត្យឃើញថា ដំណើរការនៃការវិវត្តនៃបច្ចេកវិទ្យា មានលក្ខណៈដើរទៅមុខសន្សឹមៗដូចប្រទេសនានាក្នុងតំបន់ និងនៅលើពិភពលោក។ អត្ថប្រយោជន៍នៃបច្ចេកវិទ្យាទំនើប បានចូលរួមមួយចំណែកដល់ការរីកចំរើនសេដ្ឋកិច្ចជាតិគួរឱ្យកត់សម្គាល់។ រាជរដ្ឋាភិបាលកម្ពុជានាពេលបច្ចុប្បន្ននេះ បាននឹងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងលើវិស័យនេះ ដោយបានដាក់ចេញនូវចក្ខុវិស័យមួយពាក់ព័ន្ធនឹងគោលការណ៍រដ្ឋាភិបាលអេឡិចត្រូនិច (e-government)[1] ដែលបានបញ្ចូលប្រព័ន្ធបច្ចេកវិទ្យាពត៌មាន និងទំនាក់ទំនង(ICT) ទៅក្នុងប្រព័ន្ធរដ្ឋបាលរបស់ប្រទេសកម្ពុជា។ ជាក់ស្តែង ក្រសួងសាធារណការ និងដឹកជញ្ជូន(MPWT) ដែលជាសេនាធិការមួយរបស់រាជរដ្ឋាភិបាល និងមានបេសកកម្មដឹកនាំ និងរៀបចំកិច្ចការសាធារណៈ និងវិស័យដឹកជញ្ជូននៅក្នុងព្រះរាជាណាចក្រកម្ពុជា បាននឹងកំពុងអនុវត្តគោលការណ៍ e-government នៅក្នុងកិច្ចការរដ្ឋបាលជាប្រចាំថ្ងៃរបស់ខ្លួន។ ការអនុវត្តនេះ វាបានជួយជំរុញឱ្យការអនុវត្តការងាររបស់ថ្នាក់ដឹកនាំ មន្ត្រី និងការផ្តល់សេវានានារបស់ក្រសួងទៅកាន់ប្រជាពលរដ្ឋមានលក្ខណៈងាយស្រួល រហ័ស តម្លាភាព មានប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់។ លើសពីនេះទៀត ក្រសួង

[1] e-government គឺសំដៅការប្រើប្រាស់បច្ចេកវិទ្យាអ៊ិនធឺណេត សម្រាប់ប្រើប្រាស់ក្នុងការផ្លាស់ប្តូរពត៌មាន ការផ្តល់សេវាជូនប្រជាពលរដ្ឋ ការធ្វើអាជីវកម្ម និងប្រើសម្រាប់វិស័យដទៃទៀតរបស់រដ្ឋាភិបាល, ស្រង់ចេញពី https://www.igi-global.com /dictionary/electronic-government-e-government/9385

សាធារណការ និងដឹកជញ្ជូន បានបង្កើតឡើងនូវលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ដើម្បីប្រកាសដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធអនឡាញ ដែលភ្ជាប់ជាមួយនឹងសេវាសាធារណៈមួយចំនួនដែលគេអាចនិយាយបានថា « ការបំពេញសេវាតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម » រួមមាន ការចុះបញ្ជីយានយាន្ត ការចុះបញ្ជីទោចក្រយានយន្ត ការចេញលិខិតអនុញ្ញាតឱ្យយានយន្តធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោក និងការចេញលិខិតអនុញ្ញាតឱ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកជាអាទិ៍។ សេវាសាធារណៈខាងលើដែលផ្សារភ្ជាប់ជាមួយនឹងប្រព័ន្ធស្វ័យប្រវត្តិកម្ម (ប្រព័ន្ធអនឡាញ) ជាប្រភេទសេវាដែលបានធ្វើទំនើបកម្មថ្មីៗជាមួយនឹងលក្ខខណ្ឌ និងនីតិវិធី ដោយផ្លាស់ប្តូរពីការបំពេញសេវារបៀបចាស់ដែលធ្លាប់តែបំពេញឯកសារដោយដៃឱ្យ មកជារបៀបថ្មីដែលប្រើប្រាស់រួមជាមួយប្រព័ន្ធបច្ចេកវិទ្យាទំនើបដែលយើងហៅថា « ប្រព័ន្ធស្វ័យប្រវត្តិកម្ម » ជំនួសវិញ។

ដោយការមើលឃើញពីបរិបទថ្មីៗចំពោះទំនើបកម្មអំពីការផ្តល់សេវាសាធារណៈរបស់ក្រសួងសាធារណការ និងដឹកជញ្ជូនបែបនេះហើយ ទើបយើងខ្ញុំបានសម្រេចចិត្តជ្រើសរើសកំណត់យកប្រធានបទមួយស្តីពី « នីតិវិធីនៃការចុះបញ្ជីក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកតាមប្រព័ន្ធស្វ័យប្រវត្តិកម្មនៅកម្ពុជា » ដើម្បីយកមកធ្វើការស្រាវជ្រាវ។ ប្រធានបទមួយនេះ នឹងធ្វើការសិក្សាទៅលើនីតិវិធីនៃការចុះបញ្ជីតាមប្រព័ន្ធស្វ័យប្រវត្តិកម្មនេះ និងរបកគំហើញនូវបញ្ហាប្រឈមនានា ព្រមទាំងផ្តល់អនុសាសន៍ចំពោះបញ្ហាប្រឈមទាំងនោះផងដែរ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដោយហេតុថា ក្រសួងសាធារណការ និងដឹកជញ្ជូន បាននឹងកំពុងតែអនុវត្តប្រព័ន្ធស្វ័យប្រវត្តិកម្មចំពោះការផ្តល់សេវាសាធារណៈពាក់ព័ន្ធទៅនឹងការចុះបញ្ជីក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស ដូច្នេះ ៖

- តើការចុះបញ្ជីក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសតាមប្រព័ន្ធស្វ័យប្រវត្តិកម្មត្រូវប្រព្រឹត្តទៅយ៉ាងដូចម្តេច?
- តើអ្វីខ្លះជាអត្ថប្រយោជន៍នៃការចុះបញ្ជីក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម?
- តើមានបញ្ហាប្រឈម និងដំណោះស្រាយអ្វីខ្លះ ចំពោះការចុះបញ្ជីក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះ មានគោលបំណងស្វែងយល់ឱ្យបានច្បាស់លាស់អំពីនីតិវិធីនៃការចុះបញ្ជីក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសតាមប្រព័ន្ធស្វ័យប្រវត្តិ

កម្ម អត្ថប្រយោជន៍ និងបញ្ហាប្រឈមនៃដំណើរការចុះបញ្ជី ដែលបាននឹងកំពុងអនុវត្តក្នុងប្រទេសកម្ពុជា ដែលជាប្រទេសមានការអភិវឌ្ឍតិចតួច ពីព្រោះប្រជាពលរដ្ឋភាគច្រើននៅទូទាំងប្រទេស ជាពិសេសនៅតាមតំបន់ចំកាត់មាត់ញក ការយល់ដឹងរបស់ពួកគាត់នៅមានកម្រិតនៅឡើយពាក់ព័ន្ធនឹងសេវាសាធារណៈរបស់រដ្ឋ ដែលផ្សារភ្ជាប់ជាមួយនឹងបច្ចេកវិទ្យាទំនើបៗបែបនេះ។

## ៤. ដែនកំណត់នៃការស្រាវជ្រាវ

ដើម្បីធ្វើការសិក្សាស្រាវជ្រាវឱ្យបានស៊ីជម្រៅ និងជាក់លាក់លើប្រធានបទស្តីពី " នីតិវិធីនៃការចុះបញ្ជីក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកតាមប្រព័ន្ធស្វ័យប្រវត្តិកម្មនៅកម្ពុជា " យើងខ្ញុំបានដាក់សំណើទៅកាន់ក្រសួងសាធារណការ និងដឹកជញ្ជូន ហើយបានកំណត់យកនាយកដ្ឋានពត៌មានវិទ្យា និងទំនាក់ទំនងសាធារណៈ និងនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក ដើម្បីប្រមូលទិន្នន័យ និងឯកសារពាក់ព័ន្ធនានា។ ម្យ៉ាងវិញទៀត មូលដ្ឋានគតិយុត្តចម្បង គឺផ្អែកលើប្រកាសលេខ ៣៨៤ ប្រកសក ចុះថ្ងៃទី ០៦ ខែតុលា ឆ្នាំ ២០១៧ ស្តីពី " លក្ខខណ្ឌ និងនីតិវិធីនៃការចេញលិខិតអនុញ្ញាតឱ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស " ដោយធ្វើការបកស្រាយ និងផ្តល់អំណះអំណាងតែទៅលើនីតិវិធីនៃការចុះបញ្ជីក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ដោយយើងមិនធ្វើការបកស្រាយពន្យល់ពីនីតិវិធីសុំលិខិតអនុញ្ញាតឱ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស ហើយនិងនីតិវិធីសុំលិខិតអនុញ្ញាតឱ្យនីតិបុគ្គលបើកសាខាធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសនោះឡើយ។ លើសពីនេះទៀត សារណានេះក៏ផ្តោតសំខាន់តែទៅលើនីតិបុគ្គលជាក្រុមហ៊ុន ដែលបាននឹងកំពុងប្រកបអាជីវកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាប៉ុណ្ណោះ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

សារណានេះនឹងអាចរួមចំណែកជាធនធានស្រាវជ្រាវដល់ក្រសួង ស្ថាប័ននានាដែលត្រៀម ឬកំពុងតែអនុវត្តប្រព័ន្ធស្វ័យប្រវត្តិកម្មក្នុងកិច្ចការងាររដ្ឋបាលរបស់ខ្លួន ឱ្យយល់បានច្បាស់ និងអាចធ្វើការកែលម្អឱ្យមានភាពកាន់តែប្រសើរឡើង។ មួយវិញទៀត សារណានេះក៏អាចជាឯកសារជំនួយស្មារតីយ៉ាងច្រើនដល់សិស្ស និស្សិត មន្ត្រីរាជការ ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន អាជីវករ សហគ្រិន ក្រុមហ៊ុនឯកជននានាដែលមានបំណងក្នុងការបើកអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស ដើម្បីធ្វើការសិក្សាស្រាវជ្រាវបន្ត និងធ្វើការអភិវឌ្ឍបន្ថែមទៀតទៅលើអ្វីដែលមានថ្មី ដែលជាប្រយោជន៍ដល់សង្គមជាតិទាំងមូល។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទនេះ យើងខ្ញុំបានប្រើប្រាស់វិធីសាស្ត្រសំខាន់ៗដូចខាង

ក្រោមនេះ៖

- ការប្រមូលទិន្នន័យ៖
  - ទិន្នន័យចម្បង (Primary Data) ជាប្រភេទទិន្នន័យផ្ទាល់ ដែលយើងខ្ញុំបានចុះទៅកាន់នាយកដ្ឋានពត៌មានវិទ្យា និងទំនាក់ទំនងសាធារណៈ និងនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក ចំនួន២សប្តាហ៍ ដើម្បីប្រមូលទិន្នន័យដោយផ្ទាល់ តាមរយៈការបង្កើតកម្រងសំណួរយកទៅសាកសួរផ្ទាល់ជាមួយមន្ត្រីជំនាញនៅនាយកដ្ឋានទាំងពីរនោះ។
  - ទិន្នន័យបន្ទាប់បន្សំ (Secondary Data) ជាប្រភេទទិន្នន័យដែលទទួលបានមកតាមរយៈគេហទំព័ររបស់ក្រសួងសាធារណការ និងដឹកជញ្ជូន គេហទំព័រពត៌មាននានា ឯកសារពាក់ព័ន្ធនានាដែលក្រសួងផ្តល់ឱ្យ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀតដូចជា ច្បាប់ ប្រកាសពាក់ព័ន្ធ សេចក្តីជូនដំណឹង -ល-។
- ការវិភាគទ្រឹស្តី និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងនីតិវិធីនៃការចុះបញ្ជីក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកតាមប្រព័ន្ធស្វ័យប្រវត្តិកម្មនៅកម្ពុជា។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះ ចែកចេញដូចខាងក្រោមនេះ៖

**សេចក្តីផ្តើម** ចំណុចនេះនឹងបង្ហាញអំពីលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ដែនកំណត់នៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

ជំពូកទី ១ **"សញ្ញាណទូទៅនៃប្រព័ន្ធស្វ័យប្រវត្តិកម្ម"** បង្ហាញអំពីទិដ្ឋភាពទូទៅនៃការចុះបញ្ជីក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស អំពីអត្ថប្រយោជន៍នៃប្រព័ន្ធស្វ័យប្រវត្តិកម្ម ទិដ្ឋភាពទូទៅនៃការអនុវត្តប្រព័ន្ធស្វ័យប្រវត្តិកម្មនៅក្នុងវិស័យដឹកជញ្ជូនផ្លូវគោក និយមន័យនៃពាក្យគន្លឹះមួយចំនួនជាដើម។

ជំពូកទី ២ **"នីតិវិធីនៃការចុះបញ្ជីក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម"** បង្ហាញអំពីនីតិវិធីនៃការចុះបញ្ជីក្រុមហ៊ុន តួនាទីរបស់អ្នកដាក់ពាក្យស្នើសុំ និងមន្ត្រីផ្តល់សេវាទៅតាមដំណាក់កាលនីមួយៗ កាតព្វកិច្ចក្រោយការចុះបញ្ជី ការអស់សុពលភាពនៃវិញ្ញាបនបត្រ។

ជំពូកទី ៣ **"ការពិភាក្សាលើនីតិវិធីនៃការចុះបញ្ជីក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម"** លោកអ្នកនឹងបានស្វែងយល់អំពីចំណុចខ្លាំង ចំណុចខ្សោយ បញ្ហាប្រឈម កាលានុវត្តភាព និងដំណោះស្រាយចំពោះបញ្ហាប្រឈមនោះ។

**សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ៖** បន្ទាប់ពីការសិក្សាលើជំពូកទាំងបី យើងខ្ញុំនឹងធ្វើការសន្និដ្ឋានសរុបទៅលើសារណាទាំងមូល ព្រមទាំងផ្តល់អនុសាសន៍ចម្បងៗ ដែលយើងខ្ញុំបានស្រាវជ្រាវស្វែងយល់ពីប្រធានបទនេះ។

**ឯកសារយោង**

**បញ្ជីឧបសម្ព័ន្ធ**

# ជំពូកទី ១ សញ្ញាណទូទៅនៃប្រព័ន្ធស្វ័យប្រវត្តិកម្ម

## ១.១ អ្វីទៅជាប្រព័ន្ធស្វ័យប្រវត្តិកម្ម?

ប្រព័ន្ធស្វ័យប្រវត្តិកម្ម (Online Automation System) គឺជាសំណុំនៃកម្មវិធី ប្រើប្រាស់តាមរយៈកុំព្យូទ័រ ដែលគ្រប់បណ្ដាញ និងដំណើរការទាំងអស់ដោយមិនចាំបាច់ត្រូវការចំណាយកម្លាំងរបស់មនុស្សឡើយ។ ម្យ៉ាងទៀត ប្រព័ន្ធស្វ័យប្រវត្តិកម្មដំណើរការតាមរយៈបច្ចេកវិទ្យាទំនើប (កុំព្យូទ័រ) ដើម្បីជួយសម្រួលបន្ទុកដល់ភ្នាក់ងារប្រតិបត្តិក្នុងការចុះបញ្ជីអាជីវកម្ម ជាពិសេស ប្រព័ន្ធស្វ័យប្រវត្តិកម្ម គឺជាផ្នែកមួយដ៏សំខាន់ នៃការត្រួតពិនិត្យប្រព័ន្ធដោយស្វ័យប្រវត្តិ ដែលដំណើរការនេះត្រូវបានធ្វើឡើងដោយស្វ័យប្រវត្តិទាំងស្រុង។ ក្នុងនិយមន័យមួយផ្សេងទៀតនោះ ប្រព័ន្ធស្វ័យប្រវត្តិកម្ម គឺជាការរួមបញ្ចូលគ្នានៃកម្មវិធី និងឯកសារទាំងអស់ ដែលបានបង្កើតឡើង និងដាក់ឱ្យដំណើរការដោយស្វ័យប្រវត្តិដោយមិនត្រូវការមនុស្សដើម្បីមកផ្ដល់ពត៌មាន និងធ្វើការណែនាំសម្រាប់ប្រតិបត្តិការនីមួយៗឡើយ។[2]

## ១.២ អត្ថប្រយោជន៍នៃប្រព័ន្ធស្វ័យប្រវត្តិកម្ម

អត្ថប្រយោជន៍មួយចំនួននៃដំណើរការប្រព័ន្ធស្វ័យប្រវត្តិកម្មមានដូចជា ៖

- លុបបំបាត់ហានិភ័យនៃកំហុសរបស់មនុស្ស មានន័យថា រាល់ការអនុវត្តរបស់មនុស្ស គឺតែងតែមាននូវកំហុសជានិច្ចកាល ប៉ុន្តែសម្រាប់ដំណើរការប្រព័ន្ធស្វ័យប្រវត្តិកម្មដែលប្រើប្រាស់តាមរយៈបច្ចេកវិទ្យាទំនើបវិញ គឺមានភាពច្បាស់លាស់ និងមិនមានកំហុសកើតឡើងឡើយ។
- បង្កើនផលិតភាពអ្នកប្រើប្រាស់ គឺសំដៅទៅលើការចុះបញ្ជីដែលមានភាពងាយស្រួល មិនពិបាក និងមិនប្រើពេលយូរដូចពីមុន នៅដែលមិនទាន់មានប្រព័ន្ធស្វ័យប្រវត្តិកម្ម នេះជាហេតុជំរុញឱ្យនីតិបុគ្គល ដែលមានបំណងចង់ចុះបញ្ជីអាជីវកម្មមានការកើនឡើងជាលំដាប់។
- ផ្ដល់ជូននូវប្រតិបត្តិការដែលមានលក្ខណៈស្តង់ដារ មានន័យថាប្រតិបត្តិការទាំងអស់នៅក្នុងការចុះបញ្ជីគឺប្រព្រឹត្តទៅមានភាពត្រឹមត្រូវ និងមានការទទួលស្គាល់ជាលក្ខណៈផ្លូវការ។
- ផ្ដល់នូវការគ្រប់គ្រងប្រតិបត្តិការ និងការកត់ត្រាដ៏ល្អប្រសើរមួយ គឺសំដៅទៅលើការអនុវត្ត និងការរក្សាទុកនូវឯកសារដែលមានសុវត្ថិភាព គ្មានហានិភ័យចំពោះការបាត់បង់។

## ១.៣ ទិដ្ឋភាពទូទៅនៃការអនុវត្តប្រព័ន្ធស្វ័យប្រវត្តិកម្មក្នុងវិស័យសេវាសាធារណៈមួយចំនួននៅប្រទេសកម្ពុជា

សេចក្ដីរំពឹងលើសេវាសាធារណៈរបស់ប្រជាពលរដ្ឋកម្ពុជាកាន់តែមានភាពកើនឡើងក្នុងបរិបទ

---

[2] ដកស្រង់ចេញពីវេបសាយ www.technopedia.com

នៃសាកលភាវូបនីយកម្ម និងសមាហរណកម្មរបស់កម្ពុជានៅក្នុងសមាគមអាស៊ាន។ ដោយហេតុប្រទេសមានការរីកចម្រើន សេវាសាធារណៈក៏ត្រូវមានការវិវត្តដូចគ្នាដែរ។ ការលើកកម្ពស់គុណភាពសេវាសាធារណៈជាកិច្ចការអាទិភាព និងបន្ទាន់របស់រាជរដ្ឋាភិបាល។ ហេតុដូចនេះហើយ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ ព្រមជាមួយនឹងគោលនយោបាយជាច្រើន ជាពិសេសគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈដែលអនុម័តដោយគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៦ ដែលគោលនយោបាយនេះផ្តល់ឱ្យក្រសួង-ស្ថាប័ននូវវិធីសាស្ត្រ និងយន្តការនានា ដើម្បីកែលម្អគុណភាព និងផ្តល់សេវារបស់ក្រសួង-ស្ថាប័នជូនប្រជាពលរដ្ឋតាមតម្រូវការ នៅតាមទីកន្លែង និងទាន់ពេលវេលា។ ទន្ទឹមជាមួយគ្នានេះផងដែរ គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ បានដាក់ចេញនូវកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨ ដោយបានឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ បានដាក់ចេញនូវផែនការសកម្មភាព ២០១៥-២០១៨ ដោយធ្វើការពង្រឹងគុណភាព និងប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ ដោយក្នុងនោះត្រូវសិក្សា និងជំរុញការផ្តល់សេវាសាធារណៈតាមប្រព័ន្ធពត៌មានវិទ្យា។ ក្នុងលក្ខខណ្ឌបែបនេះហើយ ដែលយើងអាចសង្កេតឃើញថា នាពេលឥឡូវនេះ ក្រសួង-ស្ថាប័ន គ្រឹះស្ថានសាធារណៈមួយចំនួនធំនៅកម្ពុជាបាននឹងកំពុងតែយកចិត្តទុកដាក់ផ្តល់សេវាសាធារណៈរបស់ខ្លួន ដោយមានផ្សារភ្ជាប់ជាមួយបច្ចេកវិទ្យាទំនើប។

ជាក់ស្តែង ក្រសួងពាណិជ្ជកម្មនាពេលសព្វថ្ងៃនេះ បានដាក់ឱ្យអនុវត្តនូវការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្មតាមរយៈគេហទំព័រ៖ www.businessregistration.moc.gov.kh។[3] សេវាសាធារណៈមួយនេះ កើតចេញពីលទ្ធផលនៃការកែទម្រង់ស៊ីជម្រៅជាបន្តបន្ទាប់ សំដៅដល់ការពង្រឹងយន្តការ និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈជូនដល់វិស័យឯកជនឱ្យកាន់តែមានភាពងាយស្រួល រហ័ស និងធានាដល់បរិយាកាសនៃការធ្វើធុរកិច្ចនៅកម្ពុជាឱ្យកាន់តែមានភាពប្រសើរឡើង។

មួយវិញទៀត សាលាភូមិន្ទរដ្ឋបាល ជាគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលមានបេសកកម្មបណ្តុះបណ្តាលសិស្សមន្ត្រី និងមន្ត្រីរាជការនៃព្រះរាជាណាចក្រកម្ពុជា។ ជារៀងរាល់ឆ្នាំ សិស្សនិស្សិត និងមន្ត្រីរាជការជាច្រើនបានដាក់ពាក្យប្រឡងប្រជែង ដើម្បីទទួលបានការសិក្សានៅទីនោះ។ ការដាក់ពាក្យប្រឡង គឺ អនុវត្តឡើងដោយបំពេញពាក្យសុំដោយដៃ និងយកមកដាក់នៅ

[3] សូមអានប្រកាសលេខ ២១៣ ព.ណ ចបព .ប្រក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម

សាលាភូមិន្ទរដ្ឋបាល។ តែនាពេលបច្ចុប្បន្ននេះ សាលាភូមិន្ទរដ្ឋបាលបានធ្វើនុវានុវត្តន៍ទៅលើនីតិវិធីនៃការដាក់ពាក្យប្រឡង ដោយជំនួសពីការដាក់ពាក្យដែលធ្លាប់តែបំពេញដោយដៃ មកប្រើប្រាស់កុំព្យូទ័រ និងប្រព័ន្ធអនឡាញជំនួសវិញ។ ជាក់ស្តែង ការប្រឡងប្រជែងជ្រើសរើសសិស្សមន្ត្រីជាន់ខ្ពស់ជំនាន់ទី១០ ដែលបានប្រព្រឹត្តទៅកាលពី ខែវិច្ឆិកា ឆ្នាំ២០១៧ សិស្ស និស្សិត ឬមន្ត្រីរាជការ ដែលចង់ប្រឡងចូលរៀនត្រូវដាក់ពាក្យសុំតាមប្រព័ន្ធអនឡាញដែលមានគេហទំព័រ៖ sms.era.gov.kh ។[4] ការធ្វើនុវានុវត្តន៍បែបនេះ បានធ្វើឱ្យមានភាពងាយស្រួលទាំងមន្ត្រីផ្តល់សេវា និងអ្នកដាក់ពាក្យ។

ក្រៅពីនេះ យើងគួរសិក្សាផងដែរ អំពីការបង់ពន្ធគយនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ សូមសិក្សាលើករណីប្រមូលពន្ធយានយន្តនៅកម្ពុជាបន្តិច ដោយនាពេលបច្ចុប្បន្ននេះ ដើម្បីប្រមូលពន្ធយានយន្តឱ្យមានប្រសិទ្ធភាព រាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានសហការគ្នា ដើម្បីតភ្ជាប់ប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីយានយន្ត ជាមួយប្រព័ន្ធទិន្នន័យពន្ធគយ។ នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៨ ក្រសួងសាធារណការ និងដឹកជញ្ជូន បានធ្វើការតភ្ជាប់ប្រព័ន្ធស្វ័យប្រវត្តិកម្មដឹកជញ្ជូនផ្លូវគោក ជាមួយប្រព័ន្ធទិន្នន័យពន្ធគយរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានសម្រេចដោយជោគជ័យក្នុងការតភ្ជាប់ប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ និងប្រព័ន្ធស្វ័យប្រវត្តិកម្មដឹកជញ្ជូនផ្លូវគោក។ ការតភ្ជាប់ប្រព័ន្ធនេះ នឹងធ្វើការផ្ទៀតផ្ទាត់លេខសម្គាល់សន្លឹកពន្ធនាំចូល ដើម្បីទាញយកពតិមានយានយន្តមកប្រើប្រាស់ សម្រាប់ការចុះបញ្ជីយានយន្ត ដែលចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការបង្កភាពងាយស្រួលក្នុងការផ្តល់សេវា ទប់ស្កាត់ការក្លែងបន្លំឯកសារសាធារណៈ ចំណេញពេលវេលាក្នុងការចុះបញ្ជីយានយន្ត និងបង្កើនការប្រមូលចំណូលពន្ធគយផងដែរ។[5]

ទាំងអស់នេះ សបញ្ជាក់ឱ្យឃើញថា សេវាសាធារណៈនៅកម្ពុជាកំពុងតែដើរដល់ដំណាក់កាលមួយរីកចំរើនមួយដូចប្រទេសដទៃក្នុងតំបន់ និងពិភពលោក និងឈានទៅរកឯកជនភាវូបនីយកម្មទៅថ្ងៃអនាគតជាក់ជាមិនខាន។

## ១.៤ ទិដ្ឋភាពទូទៅនៃការអនុវត្តប្រព័ន្ធស្វ័យប្រវត្តិកម្មក្នុងវិស័យដឹកជញ្ជូនផ្លូវគោក

យើងបានសិក្សាស្វែងយល់ពីខាងលើរួចមកហើយថាអ្វីទៅជាប្រព័ន្ធស្វ័យប្រវត្តិកម្ម និងអត្ថប្រយោជន៍របស់វា នៅក្រសួងសាធារណការ និងដឹកជញ្ជូននៃព្រះរាជាណាចក្រកម្ពុជា បានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការធ្វើកំណែទម្រង់ការងារ ដោយបាននឹងកំពុងប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិ

[4] សេចក្តីជូនដំណឹងលេខ ៩៩៩ ស.ភ.រ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការប្រឡងប្រជែងសិស្សមន្ត្រីជាន់ខ្ពស់ជំនាន់ទី១០

[5] ដកស្រង់ចេញពី៖ http://www.propertyarea.asia/

កម្មក្នុងការគ្រប់គ្រង និងការផ្តល់សេវាកម្មក្នុងវិស័យដឹកជញ្ជូនជំនួសឱ្យពេលមុនដែលប្រើដៃ។[6] នៅក្នុងវិស័យដឹកជញ្ជូនផ្លូវគោក នាយកដ្ឋានដឹកជញ្ជូនផ្លូវគោកបានដាក់ឱ្យអនុវត្តនូវប្រព័ន្ធស្វ័យប្រវត្តិកម្មក្នុងការគ្រប់គ្រង និងការផ្តល់សេវាកម្មសាធារណៈដែលសម្រេចបានលទ្ធផលដូចខាងក្រោមនេះ[7]៖

- បានដាក់ឱ្យប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្មសម្រាប់ហាងលក់យានយន្ត ចំនួន ២១០ កន្លែង ក្នុងនោះហាងលក់ទោចក្រយានយន្តសុទ្ធ ១៣៥ កន្លែង ហាងលក់ទោចក្រយានយន្ត និងរថយន្ត ៥៨ កន្លែង និងហាងលក់រថយន្តសុទ្ធ ១៧ កន្លែង

- បានចុះបញ្ជីយានជំនិះសរុបចំនួន ៤២៣,៦៥២ គ្រឿង ក្នុងនោះទោចក្រយានយន្តមានចំនួន ៣៦៤,៣៤៣ គ្រឿង និងរថយន្តគ្រប់គ្រងចំនួន ៥៩,៣០៩ គ្រឿង

- បានផ្តល់បណ្ណបើកបរយានយន្ត ចំនួនសរុប ៩១,៥១៦ បណ្ណ ក្នុងនោះម៉ូតូមាន ៤៩២ បណ្ណ និងមណ្ឌលប្តូរ-ពន្យារបណ្ណបើកបរនៅផ្សារទំនើប AEON Mall បានផ្តល់ចំនួន ២៣,៨៦៥ បណ្ណ

- បានផលិតវីដេអូណែនាំអំពីនីតិវិធីចុះបញ្ជីយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្មដោយសហការជាមួយ JICA

- បានបង្កើត App ទូរស័ព្ទដៃស្មាតហ្វូន សម្រាប់យល់ដឹង និងធ្វើតេស្តសាកល្បងផ្នែកទ្រឹស្តីនៃការបើកបរយានយន្ត មុននឹងប្រឡងយកបណ្ណបើកបរផ្លូវការ ហើយបច្ចុប្បន្នមានអ្នកទាញយកទៅប្រើប្រាស់ប្រមាណជាង ៤ម៉ឺននាក់

- កំពុងសហការបច្ចេកទេសរៀបចំកម្មវិធី Mobile App ដើម្បីត្រួតពិនិត្យពត៌មានយានយន្ត និងបណ្ណបើកបរសម្រាប់មន្ត្រីសមត្ថកិច្ចជំនាញប្រើប្រាស់

- កំពុងធ្វើការតភ្ជាប់ប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីយានជំនិះ ជាមួយប្រព័ន្ធទិន្នន័យពន្ធគយរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ដើម្បីសម្រួលដល់នីតិវិធីក្នុងការផ្ទៀងផ្ទាត់បានឆាប់រហ័ស និងមានប្រសិទ្ធភាពខ្ពស់ ព្រមទាំងកាត់បន្ថយការក្លែងបន្លំ។

---

[6] របាយការណ៍ស្តីពីលទ្ធផលការងាររបស់អគ្គនាយកដ្ឋានផ្លូវគោកប្រចាំឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨, ទំព័រ៤

[7] សន្ទរកថា **ឯកឧត្តម ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូនក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០១៧ និងទិសដៅការងារឆ្នាំ២០១៨ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៨ ទំព័រ ៣ នៅសាលសន្និសីទចតុម្មុខ

## ១.៥ និន្នាការទូទៅនៃការចុះបញ្ជីក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសតាមប្រព័ន្ធស្វ័យប្រវត្តិកម្មនៅក្រសួងសាធារណការ និងដឹកជញ្ជូន

ដើម្បីងាយស្រួលក្នុងការសិក្សាទៅលើនៅចំណុចនេះ យើងគួរសិក្សានូវពាក្យគន្លឹះមួយចំនួនដូចខាងក្រោមនេះជាមុនសិន៖

- ក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស គឺសំដៅដល់ក្រុមហ៊ុនក្នុងប្រទេសទាំងអស់ដែលធ្វើអាជីវកម្មដឹកជញ្ជូនទំនិញ អ្នកដំណើរ ភ្នាក់ងារផ្តល់សេវាដឹកជញ្ជូន ឬសេវាកម្មជួលរថយន្តត្រូវមានវិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោក ដែលក្នុងនោះ៖

- ក្រុមហ៊ុនធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវទំនិញ អ្នកដំណើរ សំដៅលើនីតិបុគ្គលដែលធ្វើអាជីវកម្ម ដឹកជញ្ជូនទំនិញ ដឹកជញ្ជូនអ្នកដំណើរ ដោយប្រើប្រាស់រថយន្ត។ ឧទាហរណ៍៖ ក្រុមហ៊ុនកាពីតូលទេសចរណ៍ដឹកអ្នកដំណើរ ក្រុមហ៊ុនមេគង្គអ៊ិចប្រេស ក្រុមហ៊ុនម៉ីហុងដឹកអ្នកដំណើរ -ល-។
- ភ្នាក់ងារផ្តល់សេវាដឹកជញ្ជូន គឺសំដៅដល់នីតិបុគ្គលដែលផ្តល់សេវាកម្មដឹកជញ្ជូនទំនិញ ឬដឹកជញ្ជូនអ្នកដំណើរ ដោយមាន ឬគ្មានរថយន្ត ដើម្បីយកកម្រៃ ក្នុងនោះរាប់បញ្ចូលទាំងភ្នាក់ងារ ផ្តល់សេវាដឹកជញ្ជូន ដែលធ្វើប្រតិបត្តិការ ឬគាំទ្រសកម្មភាពដឹកជញ្ជូនដោយប្រព័ន្ធចែករំលែកយានជំនិះតាមមធ្យោបាយអេឡិចត្រូនិច។ ឧទាហរណ៍៖ ក្រុមហ៊ុន PassApp Taxi ក្រុមហ៊ុន Uber Taxi ក្រុមហ៊ុនGrab Taxi ក្រុមហ៊ុនDHL ក្រុមហ៊ុន WeGO Taxi និងក្រុមហ៊ុន ជី អូ វីហ្គោ ឯ.ក (G.O WEGO co.LTD) ជាដើម។
- សេវាកម្មជួលរថយន្ត សំដៅលើនីតិបុគ្គលដែលផ្តល់សេវាជួលរថយន្តសម្រាប់ជាមធ្យោបាយដឹកជញ្ជូនទំនិញ ឬអ្នកដំណើរ។ ឧទាហរណ៍៖ ក្រុមហ៊ុនទេសចរណ៍ វើលដ៍ អ៊ិចប្រេស (World Express Tour& Travel) ជាដើម។[8]

- ការចុះបញ្ជី គឺជានីតិវិធីនៃការកត់ត្រាអំពីពត៌មានរបស់សហគ្រាសណាមួយ ក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម ឬន័យម្យ៉ាងទៀតថា គឺជាការដាក់ឈ្មោះអាជីវកម្មក្នុងបញ្ជីក្រុមហ៊ុនរបស់រដ្ឋាភិបាលរបស់ប្រទេសកម្ពុជា។[9] ប៉ុន្តែការចុះបញ្ជីនៅទីនេះ គឺសំដៅក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសទាំងអស់ ដែលមានបំណងក្នុងការបើកអាជីវកម្មរបស់ខ្លួនត្រូវតែដាក់ពាក្យស្នើសុំវិញ្ញាបនបត្រនៅអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក ដើម្បីបញ្ជាក់ពីភាពស្របច្បាប់របស់ក្រុមហ៊ុនខ្លួន។

---

[8] ប្រកាសលេខ ៣៨៤ ប្រក.សក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៧ ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការចេញលិខិតអនុញ្ញាតឱ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស, ប្រការ៨,បញ្ជីឧបសម្ព័ន្ធទី ២

[9] ដកស្រង់ចេញពីវេបសាយ៖ www.kohthmey.com

នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៤ ក្រសួងសាធារណការ និងដឹកជញ្ជូនបានចេញប្រកាសលេខ ០៣៧ សក ស្តីពីនីតិវិធីនៃការអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោក ដែលមានគោលបំណង កំណត់អំពីនីតិវិធីសម្រាប់ការអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ នៅក្នុងប្រកាសនេះផងដែរ នីតិបុគ្គល ឬរូបវន្តបុគ្គល ដែលមានប្រកបអាជីវកម្មដឹកជញ្ជូនតាមផ្លូវគោក ត្រូវមានវិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោក។ មិនត្រឹមតែប៉ុណ្ណោះ គេឃើញមានការលើកឡើងពី នីតិវិធីនៃការផ្តល់សេវាស្នើសុំវិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោក លិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោក លិខិតអនុញ្ញាតបើកសាខាធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោក និងលិខិតអនុញ្ញាតយានយន្តធ្វើអាជីវកម្មដឹកជញ្ជូន។[10] នៅក្នុងការបំពេញសេវាទាំងអស់នេះ គឺគេអនុវត្តឡើងដោយប្រើប្រាស់ដៃ និងការប្រើប្រាស់ឯកសារក្រដាសស្នាមមួយចំនួន។ ការបំពេញសេវាសាធារណៈមួយនេះបានធ្វើឱ្យកើតមានឡើងនូវបញ្ហាប្រឈមមួយចំនួនដូចជា ការយឺតយ៉ាវ នីតិវិធីសាំញ៉ាំ ចំណាយពេលយូរ គ្មានប្រសិទ្ធភាព ការបាត់ឯកសារ ការិយាធិបតេយ្យ អំពើពុករលួយ និងមិនមានលក្ខណៈស្តង់ដារជាដើម។

ដោយមើលឃើញពីបញ្ហាបែបនេះហើយ ទើបអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក បានចាប់ផ្តើមដាក់ឱ្យអនុវត្តប្រកាសលេខ ៣៨៣ ប្រក.សក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៧ ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការចេញលិខិតអនុញ្ញាតឱ្យយានយន្តធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស និងប្រកាសលេខ ៣៨៤ ប្រក.សក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៧ ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការចេញលិខិតអនុញ្ញាតឱ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស ដោយដាក់ឱ្យដំណើរការនូវប្រព័ន្ធស្វ័យប្រវត្តិកម្មអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសចាប់ពី ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៧ តាមរយៈគេហទំព័រ transportlicense.mpwt.gov.kh។[11] ប្រកាសលេខ ៣៨៣ និងលេខ ៣៨៤ ខាងលើនេះបានធ្វើឱ្យនិរាករណ៍ទៅលើបញ្ញត្តិទាំងឡាយដែលមានចែងនៅក្នុងប្រកាសលេខ ០៣៧ ប្រក.សក ទាំងអស់។ តែបើតាមការសង្កេតមើលទៅ ប្រកាសទាំងបីនេះនៅមានចែងចង្អុលបង្ហាញពីលក្ខខណ្ឌ និងនីតិវិធីមួយចំនួនដែលដូចគ្នាខ្លះៗដែរ។

នៅក្នុងការអនុវត្តប្រកាសលេខ ៣៨៤ ប្រក.សក នៅពេលនេះគឺ ពាក្យសុំវិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស លែងឆ្លងកាត់ការសម្រេចចុងក្រោយរបស់រដ្ឋមន្ត្រីក្រសួង

[10] សូមអានប្រកាសលេខ ០៣៧ ប្រក.សក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៤ ស្តីពីនីតិវិធីនៃការអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោក

[11] សេចក្តីជូនដំណឹងលេខ ៧៩២ សក.ដជគ ចុះថ្ងៃទី២៩ ខែវិច្ឆកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យដំណើរការប្រព័ន្ធស្វ័យប្រវត្តិកម្មអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស,បញ្ជីឧបសម្ព័ន្ធទី ២

សាធារណការ និងដឹកជញ្ជូនដូចមុនទៀតហើយ គឺ ត្រូវសម្រេចចុងក្រោយត្រឹមតែអគ្គនាយកនៃអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោកតែប៉ុណ្ណោះ។ មួយវិញទៀត វិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស មានភ្ជាប់មកជាមួយនូវ QR code ហើយលែងមានការចុះហត្ថលេខាដូចការអនុវត្តនៅក្នុងប្រកាសលេខ ០៣៧ ទៀតហើយ ដែលវាជាទំនើបកម្មសេវាកម្មមួយថ្មីរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ក្នុងការគ្រប់គ្រងក្រុមហ៊ុនដែលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកនៅក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យមានប្រសិទ្ធភាពខ្ពស់ និងឱ្យបានល្អប្រសើរឡើង។[12]

យ៉ាងណាមិញ ក្នុងការដាក់ឱ្យដំណើរការនូវគេហទំព័រ transportlicense.mpwt.gov.kh នេះ គឺស្ថិតនៅក្នុងដំណាក់កាលកំពុងសាកល្បង (ដំណាក់កាលពាក់កណ្ដាលស្វ័យប្រវត្តិកម្ម) នៅឡើយ។ ក្នុងការតម្លើងឱ្យប្រើប្រាស់នូវប្រព័ន្ធស្វ័យប្រវត្តិកម្មនេះ ក្រសួងបានទទួលជំនួយឧបត្ថម្ភពីក្រុមហ៊ុនត្រួតពិនិត្យបច្ចេកទេសយានយន្តនៅកម្ពុជា(CMVIC)[13] និងតម្លើងដោយក្រុមហ៊ុន ខេម អ៊ិនហ្វូ សឺវីស (Cam Info Services)[14] ។

[12] ប្រកាសលេខ ៣៨៥ ប្រក.សក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៧ ស្ដីពីលក្ខខណ្ឌ និងនីតិវិធីនៃការចេញលិខិតអនុញ្ញាតឱ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស,ឧបសម្ព័ន្ធទី ២, បញ្ជីឧបសម្ព័ន្ធទី ២

[13] ក្រុមហ៊ុនត្រួតពិនិត្យបច្ចេកទេសយានយន្តនៅកម្ពុជា (CMVIC) ជាក្រុមហ៊ុនដែលទទួលបានសិទ្ធិផ្ដល់សេវាត្រួតពិនិត្យបច្ចេកទេសយានយន្តពីក្រសួងសាធារណការ និងដឹកជញ្ជូន

[14] វេបសាយរបស់ក្រុមហ៊ុនគឺ http://www.caminfoservices.com/

# ជំពូកទី ២ នីតិវិធីនៃការចុះបញ្ជីក្រុមហ៊ុន អាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម

## ២.១ ដំណាក់កាលសំខាន់ៗនៃនីតិវិធីក្នុងការចុះបញ្ជីក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម

### ២.១.១ ដំណាក់កាលអ្នកដាក់ពាក្យស្នើសុំ( នីតិបុគ្គល ឬតំណាងស្របច្បាប់)

នីតិវីធីស្នើសុំចុះបញ្ជីក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស តាមប្រព័ន្ធស្វ័យប្រវត្តិកម្មក្នុងដំណាក់កាលនេះត្រូវមានលក្ខខណ្ឌ និងឆ្លងកាត់ពីរដំណាក់កាលមានដូចជា ដំណាក់កាលទី១ គឺជាដំណាក់កាលប្រមូលឯកសារពាក់ព័ន្ធ ដំណាក់កាលទី២ គឺជាដំណាក់កាលអនុវត្តផ្ទាល់តាមរយៈប្រព័ន្ធស្វ័យប្រវត្តិកម្ម។

ដើម្បីជៀសវាងកំហុសឆ្គងដែលអាចនឹងកើតឡើងក្នុងការស្នើសុំសេវា ដូចនេះនៅក្នុងដំណាក់កាលនីមួយៗ ទាមទារតម្រូវឱ្យអ្នកដាក់ពាក្យស្នើសុំត្រូវតែមានការស្វែងយល់ឱ្យបានច្បាស់លាស់ជាមុនសិន។

#### ២.១.១.១ ដំណាក់កាលប្រមូលឯកសារពាក់ព័ន្ធ

##### ២.១.១.១.១ លក្ខខណ្ឌ

កត់សម្គាល់ផងដែរថា អ្នកស្នើសុំធ្វើអាជីវកម្មសំដៅដល់បុគ្គលទាំងឡាយណាដែលច្បាប់ផ្តល់សិទ្ធិ និងកាតព្វកិច្ចទៅឱ្យក្នុងការសុំធ្វើវិញ្ញាបនបត្រធ្វើអាជីវកម្មដឹកជញ្ជូនតាមផ្លូវគោក។ បុគ្គលទាំងនោះអាចជាសហកម្មសិទ្ធិករ ឯកកម្មសិទ្ធិករ ឬអ្នកតំណាងស្របច្បាប់របស់នីតិបុគ្គល ឬក្រុមហ៊ុននោះ។ បន្ថែមពីនេះទៅទៀត ក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទសទាំងអស់ត្រូវមានឯកសារគ្រប់គ្រាន់ដូចចំនុច ២.១.១.១.២ ខាងក្រោមនេះ។

##### ២.១.១.១.២ ការប្រមូលឯកសារ

ក្នុងការដំណាក់កាលនេះ ដើម្បីទទួលបានវិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស ម្ចាស់ក្រុមហ៊ុន ឬអ្នកតំណាងស្របច្បាប់របស់ក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនទំនិញ អ្នកដំណើរ ភ្នាក់ងារផ្តល់សេវាដឹកជញ្ជូន និងសេវាកម្មជួលរថយន្តតម្រូវឱ្យភ្ជាប់ជាមួយនូវឯកសារមួយចំនួន។

ក្នុងការដំណាក់ប្រមូលឯកសារនេះ ឯកសារទាំងនោះត្រូវតែជាឯកសារស្របច្បាប់ដែលមានដូចខាងក្រោមនេះ៖

- អត្តសញ្ញាណប្រធានក្រុមហ៊ុន (អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ក្នុងករណីក្រុមហ៊ុនមានសញ្ជាតិខ្មែរ) និងលិខិតឆ្លងដែន (ក្នុងករណីក្រុមហ៊ុន

មានសញ្ជាតិបរទេស[15])។ ឯកសារទាំងអស់នេះចាំបាច់ត្រូវបញ្ជាក់ពីនីត្យានុកូលកម្មពីសាលាខណ្ឌ ឬសាលាក្រុង ឬសាលាស្រុកជាមុនសិន ដើម្បីជាការងាយស្រួលក្នុងការចុះបញ្ជី។[16]

- វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្ម (ត្រូវបញ្ជាក់ពីនីត្យានុកូលកម្មពីសាលាខណ្ឌ ឬសាលាក្រុង ឬសាលាស្រុកជាមុនសិន)។ វិញ្ញបនបត្រនេះស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ក្រមរដ្ឋប្បវេណី និងក្រមព្រហ្មទណ្ឌដែលមានជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។[17] រាល់ពាណិជ្ជករ ឬរាល់អ្នកដឹកនាំក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយណា ដែលមិនបានសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមកាលប្បញ្ញត្តិនឹងត្រូវប្តឹងទៅតុលាការអំពីបទប្រកបសកម្មភាពពាណិជ្ជកម្មមិនស្របច្បាប់។[18]

- លក្ខន្តិកៈក្រុមហ៊ុន[19] គឺជាបទប្បញ្ញត្តិដែលមានឋានានុក្រមខ្ពស់បំផុតនៅក្នុងក្រុមហ៊ុន។ លក្ខន្តិកៈនេះត្រូវតាក់តែង និងចុះហត្ថលេខាដោយភាគហ៊ុនិក ហើយអាចកែប្រែបានដោយមហាសន្និបាតភាគហ៊ុនិក។ លក្ខន្តិកៈ អាចប្រៀបប្រដូចនឹងរដ្ឋធម្មនុញ្ញរបស់ប្រទេស ពីព្រោះបទបញ្ជាផ្ទៃក្នុង គោលការណ៍ដឹកនាំ និងកិច្ចដំណើរការក្រុមហ៊ុនទាំងអស់ត្រូវអនុលោមតាមបញ្ញត្តិដែលមានកំណត់នៅក្នុងលក្ខន្តិកៈ។[20]

- ស្ថិតិរថយន្ត (ចំពោះភ្នាក់ងារផ្តល់សេវាដឹកជញ្ជូន គឺមិនតម្រូវនោះទេ)។ ស្ថិតិរថយន្ត គឺជាតារាងបង្ហាញពីចំនួនរថយន្តរបស់ក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនណាមួយ ហើយវាបង្ហាញពីប្រភេទរថយន្ត ម៉ាក លេខម៉ាស៊ីន លេខសាក់ស៊ី ផ្លាកលេខរបស់រថយន្តធ្វើអាជីវកម្មទាំងអស់នោះ។[21]

- លិខិតបញ្ជាក់ទីតាំងចំណតរថយន្ត (មិនតម្រូវចំពោះភ្នាក់ងារផ្តល់សេវាដឹកជញ្ជូនទេ)។ ហើយលិខិតនេះត្រូវតែបញ្ជាក់ដោយអាជ្ញាធរថ្នាក់មូលដ្ឋាន (ឃុំ ឬសង្កាត់)។[22]

- បណ្ណប៉ាតង់[23] (ត្រូវបញ្ជាក់ពីនីត្យានុកូលកម្មពីសាលាខណ្ឌ ឬសាលាក្រុង ឬសាលាស្រុកជាមុនសិន) គឺកំណត់អ្នកជាប់ពន្ធ ដែលពន្ធនោះជាពន្ធកំណត់លើផលរបរសរុបប្រចាំឆ្នាំដែលត្រូវបង់

---

[15] ក្រុមហ៊ុនពាណិជ្ជកម្មបរទេស ជាក្រុមហ៊ុនដែលបង្កើតឡើងក្រោមច្បាប់នៃប្រទេសដទៃ ហើយបានមកបោះទីតាំងធ្វើពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា,ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ប្រកាសឱ្យប្រើនៅ ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ ២០០៥,មាត្រា ២៧០

[16] សូមមើលគំរូអត្តសញ្ញាណបណ្ណរបស់ម្ចាស់ក្រុមហ៊ុនជី អូ វីហ្គោ ឯ.ក ,បញ្ជីឧបសម្ព័ន្ធទី ៣

[17] សូមមើលគំរូវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន ជី អូ វីហ្គោ ឯ.ក ,បញ្ជីឧបសម្ព័ន្ធទី ៣

[18] ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ប្រកាសឱ្យប្រើនៅ ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ១៩៩៥,មាត្រា៩

[19] សូមមើលគំរូលក្ខន្តិកៈរបស់ក្រុមហ៊ុន ជី អូ វីហ្គោ ឯ.ក (មានតែក្របមុខ) ,បញ្ជីឧបសម្ព័ន្ធទី ៣

[20] ដកស្រង់ចេញពី http://blog.1001stores.net/articles-of-incorporation/

[21] សូមមើលគំរូស្ថិតិរថយន្តដឹកអ្នកដំណើររបស់ក្រុមហ៊ុន ខេ អេស អូ,បញ្ជីឧបសម្ព័ន្ធទី ៣

[22] សូមមើលគំរូលិខិតបញ្ជាក់ទីតាំងចំណតរថយន្តរបស់ក្រុមហ៊ុន ជី អូ វីហ្គោ ឯ. ក,បញ្ជីឧបសម្ព័ន្ធទី ៣

ក្នុងអំឡុងពេលចាប់ពី ថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា ជារៀងរាល់ឆ្នាំ។ ដើម្បីបានបណ្ណប៉ាតង់ គឺនីតិបុគ្គលត្រូវចុះបញ្ជីនៅអគ្គនាយកដ្ឋានពន្ធដារ ហើយស្ថិតនៅក្រោមការគ្រប់គ្រងរបស់សាខាពន្ធដារណាមួយរបស់អគ្គនាយកដ្ឋានពន្ធដារ។[24]

### ២.១.១.២ ដំណាក់កាលអនុវត្តលើប្រព័ន្ធស្វ័យប្រវត្តិកម្ម

ការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្មនេះ គឺទាមទារចាំបាច់ឱ្យអ្នកស្នើសុំត្រូវតែមានកុំព្យូទ័រ ឬឧបករណ៍ឆ្លាតវៃ (Smart Phone) ដែលបានតភ្ជាប់ប្រព័ន្ធអ៊ិនធឺណេតរួចជាស្រេចទើបអាចប្រើប្រាស់បាន។ ប្រព័ន្ធនេះបានផ្តល់នូវនីតិវិធីស្នើសុំចុះបញ្ជីក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនក្នុងប្រទេសកម្ពុជាដែលកាលពីមុន គឺប្រើប្រាស់ការបំពេញសំណុំបែបបទទាំងស្រុងតាមរយៈឯកសារសរសេរដោយដៃដោយបច្ចុប្បន្នប្តូរមកប្រើបច្ចេកវិទ្យា និងប្រព័ន្ធពត៌មានវិទ្យាជំនួសវិញ។

ជាក់ស្តែងអ្នកស្នើសុំទាំងអស់ អាចអនុវត្តរាល់នីតិវិធីទាំងអស់បានដោយចូលទៅកាន់គេហទំព័រ « transportlicense.mpwt.gov.kh » ដែលជាគេហទំព័រប្រព័ន្ធស្វ័យប្រវត្តិកម្មដឹកជញ្ជូនផ្លូវគោករបស់ក្រសួងសាធារណការ និងដឹកជញ្ជូន។

សម្រាប់អ្នកស្នើសុំថ្មី ដើម្បីអាចប្រើប្រាស់ប្រព័ន្ធនេះ លោកអ្នកត្រូវតែបង្កើតគណនីនៅក្នុងគេហទំព័រ transportlicense.mpwt.gov.kh ជាមុនសិន។ ប៉ុន្តែសម្រាប់អ្នកធ្លាប់បង្កើតគណនីរួចម្តងហើយ គឺមិនចាំបាច់បង្កើតទៀតនោះទេ មានន័យថាលោកអ្នកគ្រាន់តែប្រើគណនីចាស់ដើម្បីឡុកអ៊ីន(Log In)ប្រើជាការស្រេច។ ពេលចូលទៅកាន់គេហទំព័រនេះ លោកអ្នកនឹងឃើញផ្ទាំងមួយដែលមាននិមិត្តសញ្ញា ឈ្មោះក្រសួងសាធារណការ និងដឹកជញ្ជូន ព្រមទាំងមានការសរសេរថា « ប្រព័ន្ធស្វ័យប្រវត្តិកម្មអាជីវកម្មដឹកជញ្ជូនផ្លូវគោក »។ នៅលើផ្ទាំងនោះលោកអ្នកក៏អាចធ្វើការផ្លាស់ប្តូរភាសាបានដែរ (Change Language) ពោលគឺមានទាំងភាសាខ្មែរ និងភាសាអង់គ្លេស។[25]

#### ២.១.១.២.១ ការបង្កើតគណនី

នៅលើទំព័រចុះឈ្មោះបង្កើតគណនី លោកអ្នកត្រូវបំពេញពត៌មានផ្ទាល់ខ្លួនមួយចំនួនដូចជាឈ្មោះ ពាក្យសម្ងាត់(ប្រើជាលេខរ៉ូម៉ាំង ឬភាសាអង់គ្លេស) សារអេឡិចត្រូនិច និងលេខទូរស័ព្ទ។ បន្ទាប់មកត្រូវចុចលើប្រអប់មួយដែលមានឈ្មោះថា I'm not a robot ( ជាកម្មវិធីមួយតម្រូវឱ្យលោកអ្នកបង្ហាញពីសមត្ថភាពតិចតួចក្នុងការជ្រើសរើសរូបភាព) រួចសឹមចុចលើពាក្យ « ចុះឈ្មោះ »។

ក្រោយពីចុះឈ្មោះហើយនៅផ្ទៃខាងក្រោមនៃផ្ទាំងទំព័រ នឹងមានលោតផ្ទាំងអក្សរមួយឱ្យលោក

[23] សូមមើលគំរូបណ្ណប៉ាតង់របស់ក្រុមហ៊ុន ជី អូ វីហ្គោ ឯ.ក,បញ្ជីឧបសម្ព័ន្ធទី ៣

[24] ដកស្រង់ចេញពី http://bizdoctors.asia

[25] សូមមើលគំរូគេហទំព័រ transportlicense.mpwt.gov.kh, បញ្ជីឧបសម្ព័ន្ធទី ៤

អ្នកពិនិត្យមើលសារអេឡិចត្រូនិច ( ផ្នែកអ៊ីម៉ែល) រួចលោកអ្នកត្រូវធ្វើការបញ្ជាក់ថា គណនីដែលបានបង្កើតឡើងនោះ គឺពិតជារបស់អ្នក ឬមិនមែន ដោយធ្វើការចុចលើតំណភ្ជាប់ដើម្បីបើកដំណើរការគណនី។ ករណីមិនឃើញអ៊ីម៉ែល លោកអ្នកត្រូវឆែកក្នុង Junk ឬ Spam Folder ។ បើនៅតែមិនឃើញ សូមមើលត្រង់កន្លែងបំពេញសារអេឡិចត្រូនិចរបស់លោកអ្នកម្តងទៀត បើវាពុំត្រឹមត្រូវ សូមវាយសារជាថ្មី។[26]

**២.១.១.២.២ ការចូលប្រើប្រាស់**

បន្ទាប់ពីធ្វើការបញ្ជាក់ពីភាពត្រឹមត្រូវរបស់គណនី ឬក៏ឡុកអ៊ីន (Log In) ចូលក្នុងប្រព័ន្ធទំព័រថ្មីនឹងលោតឡើងមក។ លើទំព័រនោះ មានផ្ទាំងរូបភាពចំនួន០៣ រូបទី១ គឺអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស រូបទី២ គឺអាជីវកម្មដឹកជញ្ជូនផ្លូវគោកឆ្លងដែន និងរូបភាពទី៣ គឺស្នើសុំបង់ប្រាក់បន្ថែម។ លោកអ្នកត្រូវជ្រើសរើសយកផ្ទាំងទី១ (អាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស) បន្ទាប់មកនឹងមានប្រអប់ចំនួន០២ ដែលលោកអ្នកអាចជ្រើសរើសយកបានមួយ គឺប្រអប់សំណើក្រុមហ៊ុនដឹកជញ្ជូន (ចុះបញ្ជី,លិខិតអនុញ្ញាត,បើកសាខា) និងប្រអប់សំណើលិខិតអនុញ្ញាតឱ្យយានយន្តធ្វើអាជីវកម្មដឹកជញ្ជូន។ ក្រោយពីបានជ្រើសរើសត្រូវតាមតម្រូវការហើយ លោកអ្នកនឹងឃើញកម្មវត្ថុដែលត្រូវជ្រើសរើសចំនួន០៣ ទៀតរួមមាន (១) សុំវិញ្ញាបនបត្រធ្វើអាជីវកម្មដឹកជញ្ជូន (២) សុំលិខិតអនុញ្ញាតឱ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូន និង (៣) សុំបើកសាខាធ្វើអាជីវកម្មដឹកជញ្ជូន។ លោកអ្នកត្រូវជ្រើសរើសកម្មវត្ថុទី១ បន្ទាប់មកទៀតត្រូវបំពេញរាល់ពត៌មានផ្ទាល់ខ្លួនទាំងអស់តាមការកំណត់ និងត្រូវជ្រើសរើសប្រភេទអាជីវកម្ម ឈ្មោះក្រុមហ៊ុន និងភ្ជាប់ឯកសារដែលតម្រូវ (ឯកសារត្រូវធ្វើការស្កេនជារូបភាពរួច Upload ចូល)។[27]

ក្រោយពីបំពេញគ្រប់ពត៌មាននានាហើយ គឺត្រូវបន្តទៅជំហានបន្ទាប់ទៀត។ ចូលមកដល់ទំព័រថ្មីនេះ លោកអ្នកនឹងឃើញផ្ទាំងចំនួន ០៣ គឺ (១) ផ្ទាំងពត៌មានផ្ទាល់ខ្លួនដែលលោកអ្នកបានបំពេញ (២) ផ្ទាំងតម្លៃសេវាកម្មដែលលោកអ្នកត្រូវបង់ (៣) ផ្ទាំងបង់ប្រាក់ដែលអនុញ្ញាតឱ្យលោកអ្នកធ្វើការជ្រើសរើសបាន មានដូចជា វីងអនឡាញ លីហួរវេលុយអនឡាញ និងស្មាតវេរលុយជាដើមនិង (៤) ផ្ទាំងទទួលវិក្កយបត្រ។ លោកអ្នកត្រូវពិនិត្យ និងបំពេញបែបបទនេះតាមលំដាប់ពីទី១ ដល់ទី៤។

នៅលើផ្ទាំងទី៤ ករណីដែលលោកអ្នកជ្រើសរើសការរក្សាទុក មានន័យថាទិន្នន័យទាំងអស់នោះ គឺត្រឹមត្រូវហើយវានឹងបង្ហាញពីវិក្កយបត្រចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស និង

[26] សូមមើលគេហទំព័រ transportlicense.mpwt.gov.kh ,បញ្ជីឧបសម្ព័ន្ធទី ៤

[27] សូមមើលគេហទំព័រ transportlicense.mpwt.gov.kh ,បញ្ជីឧបសម្ព័ន្ធទី ៤

ពាក្យសុំវិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស។ លោកអ្នកត្រូវធ្វើការព្រីននូវឯកសារទាំងអស់នេះដោយគ្រាន់តែចុចទៅលើពាក្យព្រីនវិក្កយបត្រ ឬព្រីនលិខិតពាក្យសុំ ឬព្រីនវិក្កយបត្រ/ពាក្យសុំ។ ក្រោយពីព្រីនឯកសារទាំងអស់នេះហើយ លោកអ្នកត្រូវចុះហត្ថលេខា និងបោះត្រាក្រុមហ៊ុនរបស់លោកអ្នកលើពាក្យសុំវិញ្ញាបនបត្រចុះបញ្ជីអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស។[28]

### ២.១.១.២.៣ ការបង់តម្លៃសេវាសាធារណៈ

ការប្រមូលកម្រៃពីសេវាសាធារណៈរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ពិតជាមានសារៈសំខាន់ណាស់ក្នុងការផ្ដល់ជាថវិកាជូនជាតិ។[29] ក្នុងន័យនេះដែរ ការផ្ដល់វិញ្ញាបនបត្រចុះបញ្ជីអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស ត្រូវបង់កម្រៃសេវាសាធារណៈតាមការកំណត់ក្នុងប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន។[30]

ដូចដែលបានជ្រាបម្ដងហើយថា ការបង់កម្រៃសេវាសាធារណៈនេះ គឺអាចបង់បានតាមរយៈក្រុមហ៊ុនដែលទទួលសិទ្ធិសហការធ្វើអាជីវកម្មពីក្រសួងសាធារណៈការ និងដឹកជញ្ជូន ដើម្បីទទួលបានសេវាសាធារណៈរបស់ក្រសួង។[31] ដូចនេះ ក្នុងការបង់ថ្លៃសេវានៃការចុះបញ្ជីក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនក្នុងប្រទេសនេះ អ្នកសុំសេវាត្រូវបង់ថ្លៃសេវាតាមភ្នាក់ងារចំនួនបី ដែលទទួលបានសិទ្ធិក្នុងការសហការធ្វើអាជីវកម្មជាមួយក្រសួងសាធារណការ និងដឹកជញ្ជូន មានដូចជាភ្នាក់ងាររីងវេរលុយ លីហួរវេរលុយ និងស្មាតវេរលុយ។

ការបង់ប្រាក់ត្រូវភ្ជាប់ទៅជាមួយផងដែរ នូវវិក្កយបត្រចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស និងពាក្យសុំវិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសដែលបានព្រីនចេញ ព្រមទាំងមានហត្ថលេខា (ម្ចាស់ក្រុមហ៊ុន ឬអ្នកតំណាង) និងត្រាក្រុមហ៊ុន។

សូមមើលតារាងខាងក្រោមនេះដែលធ្វើការបញ្ជាក់ពី តម្លៃសេវា រយៈពេលទទួលបានវិញ្ញាបនបត្រចុះបញ្ជីអាជីវកម្មដឹកជញ្ជូនផ្លូវគោក និងសុពលភាពនៃការប្រើប្រាស់។

---

[28] សូមមើលគំរូគេហទំព័រ transportlicense.mpwt.gov.kh ,បញ្ជីឧបសម្ព័ន្ធទី ៤, និងសូមមើលគំរូពាក្យសុំវិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសរបស់ក្រុមហ៊ុន ជី អូ វីហ្គោ ឯ.ក,បញ្ជីឧបសម្ព័ន្ធទី ៣

[29] ប្រកាសរួមលេខ ០១០សហវ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៦ ស្ដីពីការផ្ដល់សេវាសាធារណៈរបស់ក្រសួងសាធារណៈការ និងដឹកជញ្ជូន,ប្រការ១,បញ្ជីឧបសម្ព័ន្ធទី ២

[30] ប្រកាសលេខ ៣៨៤ ប្រក.សក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៧ ស្ដីពីលក្ខខណ្ឌ និងនីតិវិធីនៃការចេញលិខិតអនុញ្ញាតឱ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស,ប្រការ១១,បញ្ជីឧបសម្ព័ន្ធទី ២

[31] យោងតាមការសាកសួរផ្ទាល់ជាក់ស្ដែងជាមួយប្រធានការិយាល័យអាជីវកម្មដឹកជញ្ជូនក្នុងប្រទេស និងឆ្លងដែនតាមផ្លូវគោក

| ការចុះបញ្ជីក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនក្នុងប្រទេស | | | |
|---|---|---|---|
| បរិយាយ | តម្លៃសេវា(រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
| ចុះបញ្ជីក្រុមហ៊ុនដឹកជញ្ជូនផ្លូវគោក | ១ ០០០ ០០០ | ១០ ថ្ងៃ | អចិន្ត្រៃយ៍ |

## ២.១.២ ដំណាក់កាលមន្ត្រីផ្តល់សេវា

បន្ទាប់ពីអ្នកដាក់ពាក្យស្នើសុំសេវាបានបំពេញពត៌មាន និងបង់ថ្លៃសេវារួចរាល់ហើយ ពត៌មានទាំងអស់នោះ (រួមទាំងលេខប្រតិបត្តិដែលភ្នាក់ងារទទួលបង់លុយផ្ញើមក) នឹងធ្លាក់ទៅក្នុងប្រព័ន្ធមួយដែលរក្សាទុកសម្រាប់ក្រុមមន្ត្រីផ្តល់សេវាត្រួតពិនិត្យទៅតាមឋានុក្រមរដ្ឋបាល (ធ្វើការត្រួតពិនិត្យចាប់ពីថ្នាក់ការិយាល័យ រហូតដល់ថ្នាក់អគ្គនាយកដ្ឋាន)។

អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោកត្រូវ ធ្វើការរៀបចំ ត្រួតពិនិត្យ សំណុំឯកសារស្នើសុំវិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកដោយមានការត្រួតពិនិត្យ សម្រេច និងប្រថាប់ត្រារបស់អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក។[32]

នៅក្នុងដំណាក់កាលនេះ គេមានបែងចែកមន្ត្រីជាបីក្រុមទៀតគឺ៖

១. មន្ត្រីទទួលបន្ទុកខាងបញ្ជាក់ពាក្យសុំ (Verify)៖ មន្ត្រីនៅក្រុមនេះមានតួនាទីកែប្រែ និងត្រួតពិនិត្យ។ បើមន្ត្រីរកឃើញថា ពាក្យស្នើសុំនោះមិនមានលក្ខណៈត្រឹមត្រូវតាមលក្ខណ្ឌដូចដែលបានរៀបរាប់នៅក្នុងចំនុច ២.១.១.១ ខាងលើនោះទេ មន្ត្រីផ្តល់សេវាត្រូវជូនដំណឹងតាមប្រព័ន្ធអេឡិចត្រូនិចទៅកាន់អ្នកដាក់ពាក្យ ដើម្បីឲ្យពួកគេធ្វើការកែតម្រូវឡើងវិញនូវចំនុច ឬពាក្យសុំដែលខ្វះខាតជាថ្មីម្តងទៀត។ ព្រមជាមួយគ្នានេះផងដែរ បើមន្ត្រីផ្តល់សេវាត្រួតពិនិត្យមើលឃើញថាពាក្យសុំនោះត្រឹមត្រូវហើយ ពួកគាត់ត្រូវបញ្ជូនពាក្យសុំនោះមកមន្ត្រីក្រុមទី២ ដើម្បីត្រួតពិនិត្យឱ្យបានច្បាស់លាស់បន្តទៀត។

២. មន្ត្រីទទួលបន្ទុកខាងអនុម័តសម្រេច (Approval)៖ ក្រុមមន្ត្រីនេះមានតួនាទីត្រួតពិនិត្យម្តងទៀតលើពាក្យសុំនោះ បើមើលឃើញថាពាក្យសុំនោះនៅមិនទាន់ត្រឹមត្រូវ ពួកគាត់នឹងបញ្ជូនមកមន្ត្រីក្រុមទី១វិញ ដើម្បីក្រុមទី១នេះធ្វើការកែប្រែពាក្យសុំនោះជាមួយអ្នកដាក់ពាក្យសុំម្តងទៀត។

[32] សេចក្តីណែនាំលេខ ១៣៧ សក.ដជគ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីការអនុវត្តប្រកាសលេខ ៣៨៣ ប្រក.សក និងប្រកាសលេខ ៣៨៤ ប្រក.សក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៧,បញ្ជីឧបសម្ព័ន្ធទី ២

ផ្ទុយមកវិញ បើពាក្យសុំនោះត្រឹមត្រូវហើយ មន្ត្រីក្រុមទី២ នឹងបញ្ជូនមកអោយក្រុមមន្ត្រីទី៣ ដើម្បីចាត់ចែងបន្តទៀត។

៣.មន្ត្រីទទួលបន្ទុកខាងព្រីនឯកសារ៖ មន្ត្រីក្រុមនេះមានតួនាទីថតចម្លងឯកសារ និងព្រីនវិញ្ញាបនបត្រ។

ព្រមជាមួយគ្នានេះផងដែរ បើមន្ត្រីផ្តល់សេវាត្រួតពិនិត្យមើលឃើញថាពាក្យសុំនោះត្រឹមត្រូវហើយ មន្ត្រីផ្តល់សេវាត្រូវជូនដំណឹងតាមប្រព័ន្ធអេឡិចត្រូនិចទៅកាន់អ្នកដាក់ពាក្យ និងណាត់ពេលមកទទួលយកវិញ្ញាបនបត្រ ដោយភ្ជាប់មកជាមួយនូវសំណុំឯកសារតម្រូវច្បាប់ដើមជាកំហិត។[33]

## ២.១.៣ ដំណាក់កាលរវាងមន្ត្រីផ្តល់សេវា និងអ្នកដាក់ពាក្យស្នើសុំ

ចំពោះទីតាំងផ្តល់សេវា គឺការិយាល័យអាជីវកម្មដឹកជញ្ជូនក្នុងប្រទេស និងឆ្លងដែនតាមផ្លូវគោក។ ការិយាល័យនេះស្ថិតនៅក្រោមនាយកដ្ឋានដឹកជញ្ជូនផ្លូវគោកនៃអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោករបស់ក្រសួងសាធារណការ និងដឹកជញ្ជូន។[34] នៅក្នុងដំណាក់កាលនេះ អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោកត្រូវផ្ទៀងផ្ទាត់ សំណុំឯកសារស្នើសុំវិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកដោយមានការត្រួតពិនិត្យ សម្រេច និងប្រថាប់ត្រារបស់អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក។[35]

ក្រោយពីទទួលបានការជូនដំណឹងតាមប្រព័ន្ធអេឡិចត្រូនិចអំពីការណាត់ពេលទៅទទួលយកវិញ្ញាបនបត្រ លោកអ្នកត្រូវទៅបញ្ជាក់ពីភាពត្រឹមត្រូវនៃឯកសារទាំងអស់នៅទីតាំងផ្តល់សេវាដែលកំណត់ដោយក្រសួង និងត្រូវភ្ជាប់ទៅជាមួយផងដែរនូវឯកសារច្បាប់ដើមដែលបានផ្ញើតាមប្រព័ន្ធអនឡាញ ឬប្រព័ន្ធស្វ័យប្រវត្តិកម្ម ដើម្បីផ្តល់សេវាធ្វើការផ្ទៀងផ្ទាត់។

ក្នុងករណីមានកំហុស (មិនអាចកែតម្រូវបាន) មន្ត្រីផ្តល់សេវាមិនត្រូវប្រគល់វិញ្ញាបនបត្រនោះផ្ទៀងផ្ទាត់ទៅឃើញថាពិតជាត្រឹមត្រូវហើយ នោះអ្នកដាក់ពាក្យស្នើសុំនឹងទទួលបានវិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសជាស្ថាពរ។

តែបើតាមការចុះអង្កេត និងការចុះទៅសាកសួរផ្ទាល់ជាមួយប្រធានការិយាល័យអាជីវកម្មដឹកជញ្ជូនក្នុងប្រទេស និងឆ្លងដែនតាមផ្លូវគោក នីតិវិធីនៃការផ្តល់សេវានេះមានការផ្លាស់ប្តូរខ្លះៗដែល

[33] ប្រកាសលេខ ៣៩៤ ប្រក.សក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៧ ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការចេញលិខិតអនុញ្ញាតឱ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស,ឧបសម្ព័ន្ធទី១,បញ្ជីឧបសម្ព័ន្ធទី២ និងសូមមើលគំរូវិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសរបស់ក្រុមហ៊ុន ជី អូ វីហ្គោ ឯ.ក,បញ្ជីឧបសម្ព័ន្ធទី ៣

[34] ប្រកាសលេខ ២៣៩ សក.ប្រក ចុះថ្ងៃទី ១២ ខែកក្កដា ឆ្នាំ ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានដឹកជញ្ជូនផ្លូវគោក,ប្រការ២

[35] សេចក្តីណែនាំលេខ ១៣៧ សក.ដជគ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីការអនុវត្តប្រកាសលេខ ៣៩៣ ប្រក.សក និងប្រកាសលេខ ៣៩៤ ប្រក.សក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៧,បញ្ជីឧបសម្ព័ន្ធទី ២

ហាក់ដូចជាមិនស្របនឹងប្រកាសដែលមានចែងកំណត់។ ការអនុវត្តផ្លាស់ប្តូរបែបនេះ គឺដើម្បីសម្រួលដល់អ្នកសុំសេវា ដើម្បីភាពរហ័ស លឿន និងកាន់តែមានប្រសិទ្ធភាព។

ជាក់ស្តែង នៅពេលដែលម្ចាស់ក្រុមហ៊ុន ឬអ្នកតំណាងស្របច្បាប់បានបង់ថ្លៃសេវារួចរាល់ភ្លាម គាត់ត្រូវតែយកវិក្កយបត្រពាក្យសុំវិក្កយបត្របង់លុយ និងឯកសារច្បាប់ដើមទាំងអស់ទៅជួបមន្ត្រីផ្តល់សេវាតែម្តង ដើម្បីមន្ត្រីត្រួតពិនិត្យមើល ផ្ទៀងផ្ទាត់ ហើយណាត់ពេលឱ្យមកទទួលយកវិញ្ញាបនបត្រជាការស្រេច។ ដោយហេតុនេះហើយ ក្រោយពីម្ចាស់ក្រុមហ៊ុន ឬអ្នកតំណាងបានយកឯកសារច្បាប់ដើមទៅប្រគល់ឱ្យមន្ត្រីផ្តល់សេវា ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវហើយ ពេលខ្លះពួកគាត់អាចរង់ចាំទទួលយកវិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសតែបី ឬ បួនថ្ងៃប៉ុណ្ណោះ។

## ២.២ ភាពពុកិច្ចក្រោយការប្រគល់វិញ្ញាបនបត្រ

### ២.២.១ អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក

ការតម្កល់ទុកសំណុំឯកសារនៃវិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោក (មានទាំងឯកសារច្បាប់រឹង/Hard និងច្បាប់ទន់/Soft) ត្រូវតម្កល់ទុករយៈពេលយ៉ាងតិចបួនឆ្នាំ នៅអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក ។[36] ការរក្សាទុកបែបនេះ ដើម្បីភាពងាយស្រួលផ្សេងៗដូចជា៖

- ដើម្បីជាឯកសារគោលសម្រាប់ធ្វើរបាយការណ៍ប្រចាំខែ-ឆ្នាំ
- ដើម្បីបង្ការទុកជាយថាហេតុ នៅពេលណាដែលក្រុមហ៊ុនត្រូវការឯកសារទាំងអស់នោះ
- ដើម្បីផ្ទៀងផ្ទាត់ឯកសារនានា ក្នុងករណីក្រុមហ៊ុននោះមានការផ្លាស់ប្តូរម្ចាស់ក្រុមហ៊ុន ឬមានការសាខាអាជីវកម្មរបស់ខ្លួនបន្ថែមទៀត
- រក្សាទុកដើម្បីការធ្វើសវនកម្មប្រចាំឆ្នាំ។

### ២.២.២ ក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស

បន្ទាប់ពីទទួលបានវិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស ក្រុមហ៊ុនអាជីវកម្មទាំងអស់ត្រូវបង់ពន្ធជូនរដ្ឋ ដោយអនុលោមតាមច្បាប់ស្តីពីសារពើពន្ធ(១៩៩៧)។ ក្រុមហ៊ុនទាំងអស់នោះផងដែរ ត្រូវយករថយន្តធ្វើអាជីវកម្មទាំងអស់របស់ខ្លួន ទៅសុំលិខិតអនុញ្ញាតឱ្យយានយន្តធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស។[37] មួយវិញទៀត ក្រុមហ៊ុនអាជីវកម្មទាំងអស់នោះ

[36] ប្រកាសលេខ ៣៨៤ ប្រក.សក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៧ ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការចេញលិខិតអនុញ្ញាតឱ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស,ប្រការ៩,បញ្ជីឧបសម្ព័ន្ធទី ២

[37] ប្រកាសលេខ ៣៨៣ ប្រក.សក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៧ ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការចេញលិខិតអនុញ្ញាតឱ្យយានយន្តធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស,បញ្ជីឧបសម្ព័ន្ធទី ២

ត្រូវផ្តល់របាយការណ៍អំពីទិន្នផលដឹកជញ្ជូនជារៀងរាល់ខែទៅអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក។[38] របាយការណ៍អំពីទិន្នផលដឹកជញ្ជូនពិតជាមានសារៈសំខាន់ណាស់ ព្រោះក្រសួងសាធារណការ និងដឹកជញ្ជូនត្រូវការស្រង់ធ្វើជារបាយការណ៍អំពីចំនួនគ្រោះថ្នាក់ចរាចរណ៍ និងការកើនឡើង ឬការថយចុះនៃសេដ្ឋកិច្ចដឹកជញ្ជូនក្នុងប្រទេស។ មួយវិញទៀត របាយការណ៍នេះជាឯកសារដ៏ចាំបាច់សម្រាប់ក្រសួងក្នុងការបង្កើតគម្រោងនានា ជាពិសេសគម្រោងពង្រីកផ្លូវជាតិជាដើម។

## ២.៣ ការបាត់បង់សុពលភាពមុនពេលកំណត់

ថ្វីត្បិតតែវិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស មានការកំណត់យ៉ាងច្បាស់លាស់ពីសុពលភាពក៏ពិតមែន តែវានៅមានករណីមួយចំនួនដែលត្រូវអស់សុពលភាពដោយស្វ័យប្រវត្តិផងដែរ។ វិញ្ញាបនបត្រចុះបញ្ជីត្រូវបាត់បង់សុពលភាពរបស់ខ្លួន នៅក្នុងករណីដូចខាងក្រោមនេះ៖

- សាលក្រមតុលាការដែលសម្រេចហាមឃាត់ការធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោករបស់ក្រុមហ៊ុន។[39] ចំពោះមូលហេតុ ដែលនាំឱ្យមានសាលក្រមតុលាការសម្រេចហាមឃាត់ធ្វើអាជីវកម្មជញ្ជូនផ្លូវគោក គឺពុំទាន់មានលិខិតបទដ្ឋានគតិយុត្តណាមួយបញ្ជាក់ឱ្យបានច្បាស់នៅឡើយទេ ដោយទុកឆន្ទានុសិទ្ធិជូនតុលាការសម្រេច។ ទោះជាយ៉ាងណាក៏ដោយ ជាគោលការណ៍ អាជីវកម្មដែលមិនស្របច្បាប់ធ្វើឱ្យប៉ះពាល់សណ្តាប់ធ្នាប់សន្តិសុខសង្គមនឹងត្រូវរំលាយដោយតុលាការ។
- បន្ថែមពីនេះទៅទៀត ក្រុមហ៊ុនត្រូវបានលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម ក៏អាចធ្វើឱ្យវិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសបាត់បង់សុពលភាពរបស់ខ្លួនបានផងដែរ។ ចំពោះការលុបក្រុមហ៊ុនចេញពីបញ្ជីពាណិជ្ជកម្មនេះ គឺអាស្រ័យទៅតាមប្រភេទក្រុមហ៊ុន និងស្ថានភាពរបស់ក្រុមហ៊ុនទាំងនោះដូចជា ក្ស័យធន ការរំលោភទៅលើពាណិជ្ជនាម និងម៉ាករបស់ភាគីដទៃ ការមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន ការផ្លាស់ប្តូរកម្មវត្ថុនៃអាជីវកម្ម និងកត្តាបញ្ហាផ្សេងៗទៀត។[40]

---

[38] ប្រកាសលេខ ៣៥៤ ប្រក.សក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៧ ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការចេញលិខិតអនុញ្ញាតឱ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស,ប្រការ១០,បញ្ជីឧបសម្ព័ន្ធទី ២

[39] ប្រកាសលេខ ៣៥៤ ប្រក.សក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៧ ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការចេញលិខិតអនុញ្ញាតឱ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស,ប្រការ៧,បញ្ជីឧបសម្ព័ន្ធទី ២

[40] សូមមើលច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ប្រកាសឱ្យប្រើនៅ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៥ និងច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ប្រកាសឱ្យប្រើនៅ ថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០០២

# ជំពូកទី ៣ ការពិភាក្សាលើនីតិវិធីនៃការចុះបញ្ជី ក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម

## ៣.១ ចំណុចខ្លាំង

ការចុះបញ្ជីក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ជានីតិវិធីមួយដែលជាកំណែទម្រង់ថ្មីរបស់ក្រសួងសាធារណការ និងដឹកជញ្ជូនដែលទើបនឹងដាក់ឱ្យអនុវត្តនាពេលថ្មីៗនេះនៅចុងឆ្នាំ២០១៧។ ការចុះបញ្ជីតាមប្រព័ន្ធស្វ័យប្រវត្តិកម្មនេះ ជាការបម្លែងសេវាសាធារណៈមួយនេះពីសេវាដែលធ្លាប់បំពេញដោយប្រើប្រាស់ឯកសារក្រដាសស្នាម ឱ្យងាកមកប្រើប្រព័ន្ធអនឡាញជំនួសវិញ។ ទន្ទឹមនឹងនេះ យើងបានរកឃើញថា ការចុះបញ្ជីតាមប្រព័ន្ធស្វ័យប្រវត្តិកម្មនេះមានគុណសម្បត្តិយ៉ាងធំធេងចំពោះមន្ត្រីផ្តល់សេវា ប្រជាពលរដ្ឋ និងប្រទេសជាតិទាំងមូលផងដែរ។

### ក. កាត់បន្ថយការចំណាយថវិការបស់រដ្ឋ

ពិតណាស់ ការចុះបញ្ជីតាមប្រព័ន្ធស្វ័យប្រវត្តិកម្មនេះមិនទាមទារឱ្យមានការប្រើប្រាស់មន្ត្រីបំពេញសេវាច្រើនដូចមុនទេ ដែលនេះជាហេតុធ្វើឱ្យមានការកាត់បន្ថយចំនួនមន្ត្រីបំពេញការងារពីព្រោះនីតិវិធីមួយចំនួនបានប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាទំនើបជំនួសវិញ។ មិនត្រឹមតែប៉ុណ្ណោះ រដ្ឋមិនចាំបាច់ចំណាយថវិកាជាតិច្រើនទៅលើប្រាក់បៀវត្ស ឬប្រាក់ឧបត្ថម្ភផ្សេងៗរបស់មន្ត្រីទាំងអស់នោះ។

ម្យ៉ាងវិញទៀត រដ្ឋនឹងមិនចំណាយច្រើនទៀតដូចមុនទៅលើសម្ភារៈការិយាល័យ ដោយហេតុថារាល់ក្រដាសស្នាម ឬឯកសារចុះបញ្ជីមួយចំនួនធំត្រូវប្រើប្រព័ន្ធស្វ័យប្រវត្តិកម្មជំនួសវិញ។

### ខ. កាត់បន្ថយការិយាធិបតេយ្យ

ការិយាធិបតេយ្យនៅក្នុងប្រទេសកម្ពុជា គឺនៅបន្តមានជានិច្ចនៅក្នុងប្រព័ន្ធរដ្ឋបាលខ្មែរយើង ហើយវាជាក្អែលមួយដុសមិនងាយជ្រះដែលធ្វើឱ្យមានភាពយឺតយ៉ាវ ហើយនឹងគ្មានប្រសិទ្ធភាពក្នុងការបំពេញសេវាជូនប្រជាពលរដ្ឋ។

ការចុះបញ្ជីតាមប្រព័ន្ធស្វ័យប្រវត្តិកម្មនាពេលបច្ចុប្បន្ននេះ លែងមានការស្មុគស្មាញ និងប្រើប្រាស់រយៈពេលយូរទៀតហើយសម្រាប់អ្នកទទួលសេវា មានន័យថា គ្រប់ពត៌មានទាំងអស់ដែលទាក់ទងទៅនឹងនីតិវិធីបំពេញបែបបទត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយតាមប្រព័ន្ធបណ្តាញសង្គមនានា ហើយមានភាពច្បាស់លាស់ និងងាយយល់។ ការមកទទួលសេវាដែលត្រូវរង់ចាំ និងឆ្លងកាត់ដំណាក់កាលដូចមុនក៏លែងមានទៀតដែរ ហើយនេះគឺជាការកាត់បន្ថយការិយាធិបតេយ្យ ឬកាត់បន្ថយនីតិវិធីរដ្ឋបាលដែលធ្លាប់តែសាំញ៉ាំ។

### គ. កាត់បន្ថយថ្លៃធ្វើដំណើរ និងជំនួបរវាងមន្ត្រី និងអ្នកទទួលសេវា

កាលពីមុនកន្លងមក ក្នុងគ្រាដែលក្រសួងមិនទាន់ដាក់ឱ្យអនុវត្តនូវការចុះបញ្ជីក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសតាមប្រព័ន្ធស្វ័យប្រវត្តិកម្មនេះ ប្រជាពលរដ្ឋដែលមកទទួលយកសេវាត្រូវចំណាយពេលវេលា ថវិកាផ្ទាល់ខ្លួន ដើម្បីធ្វើដំណើរមកទីតាំងផ្តល់សេវាច្រើនលើកច្រើនសារ។ ប៉ុន្តែ ឥលូវនេះមិនពិបាកដូចមុនទេ វាងាយស្រួលជាងមុន គឺសេវាដែលត្រូវការនៅជិតដៃបង្កើយដោយនៅក្នុង កណ្តាប់ដៃរបស់ប្រជាពលរដ្ឋ ពីព្រោះពួកគាត់អាចស្នើសុំសេវាតាមរយៈប្រព័ន្ធស្វ័យប្រវត្តិកម្មនេះបានគ្រប់ពេលវេលា គ្រប់ទីកន្លែងដោយគ្រាន់តែមានកុំព្យូទ័រ ឬស្មាតហ្វូន (Smart Phone) និងភ្ជាប់ប្រព័ន្ធអ៊ិនធឺណេតជាការស្រេច។

ការប្រើប្រាស់ប្រព័ន្ធនេះផងដែរ បានកាត់បន្ថយជំនួបមុខផ្ទាល់រវាងអ្នកស្នើសុំ និងមន្ត្រីដោយអាចធ្វើការទាក់ទងគ្នាតាមរយៈប្រព័ន្ធអេឡិចត្រូនិច ឬទូរស័ព្ទ (Hotline)[41]បាន ប្រសិនបើមានបញ្ហាណាមួយទាក់ទងនឹងការបំពេញបែបបទ ដែលជាហេតុធ្វើឱ្យចំណេញពេលវេលា និងថវិកាយ៉ាងច្រើនដល់អ្នកសុំសេវា។

### ឃ. លុបបំបាត់ការប្រើប្រាស់វិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មក្លែងក្លាយ

ការប្រើប្រាស់វិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មក្លែងក្លាយ របស់ក្រុមហ៊ុនដឹកជញ្ជូនផ្លូវគោកនៅប្រទេសកម្ពុជានៅតែបន្តមាន។ ហេតុនេះក្រសួងសាធារណការ និងដឹកជញ្ជូន បានធ្វើការកែប្រែវិញ្ញាបនបត្រចុះបញ្ជីរបៀបថ្មីដែលមានភ្ជាប់ជាមួយនឹង QR Code ( Quick Response Code ) ដែលជាបច្ចេកវិទ្យាថ្មីមួយប្រើសម្រាប់សម្គាល់អត្តសញ្ញាណលើផលិតផលអ្វីមួយ ដោយគេអាចប្រើទូរស័ព្ទក្នុងការថតយករូបភាពនៃ QR Code នោះ ហើយវានឹងបម្លែងចេញជាពត៌មានលម្អិតជាក់លាក់។ ដូចនេះ បើសិនវិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មនោះជារបស់ក្លែងក្លាយ វានឹងមិនបង្ហាញឱ្យឃើញពីពត៌មានទាក់ទងនឹងក្រុមហ៊ុននោះទេ។

### ង. តម្លាភាពក្នុងការបង់ថ្លៃសេវា

ការបង់ថ្លៃសេវាធ្វើឡើងតាមរយៈប្រព័ន្ធស្វ័យប្រវត្តិកម្ម ដោយមានកិច្ចសហការជាមួយក្រុមហ៊ុនមួយចំនួនដូចជា លីហ្សវេរលុយ វីងវេរលុយ និងស្មាតវេរលុយជាដើម។ ការបង់ថ្លៃសេវានេះផងដែរ គឺមានការកំណត់តម្លៃប្រាប់មុនយ៉ាងច្បាស់ ហើយអ្នកស្នើសុំអាចជ្រើសរើសកន្លែងបង់ប្រាក់តាមចិត្ត និងបង់ក្នុងតម្លៃដូចៗគ្នា។ វិធីសាស្ត្រនេះធ្វើឱ្យចំណេញពេលវេលាដល់អ្នកសុំសេវា និងលុបបំបាត់ការចំណាយក្រោមតុផងដែរ។

[41] ប្រព័ន្ធទូរស័ព្ទ (Hotline) របស់ក្រសួងសាធារណការ និងដឹកជញ្ជូន៖ (០១៥/០៨៥/០៦៧) ៩២៩០៩០

**ច. លុបបំបាត់ចំណាយក្រៅផ្លូវការ**

ករណីអ្នកស្នើសុំមិនស្គាល់កន្លែងផ្តល់សេវា នោះមិនចាំបាច់រកអ្នកដទៃឱ្យជួយធ្វើបែបបទឱ្យដែលជាហេតុនាំឱ្យអស់ប្រាក់ទៀតនោះទេ ពោលគាត់អាចបំពេញបែបបទតាមប្រព័ន្ធស្វ័យប្រវត្តិកម្មបានហើយបើមានចម្ងល់ គឺអាចសាកសួរមន្ត្រីផ្តល់សេវាតាមទូរស័ព្ទបាន។

**ឆ. បង្ហាញឱ្យឃើញពីកំណែទម្រង់លើការផ្តល់សេវាសាធារណៈ**

មកទល់ពេលឥឡូវនេះ ប្រទេសកម្ពុជាបានអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈដំណាក់កាលទី៥ (២០១៥-២០១៨) មកហើយ ដែលរដ្ឋបាលសាធារណៈបាននឹងកំពុងតែធ្វើកំណែទម្រង់ឱ្យកាន់តែស៊ីជម្រៅថែមទៀត ដើម្បីក្លាយខ្លួនជាអ្នកផ្តល់សេវាដ៏មានប្រសិទ្ធភាព និងជាដៃគូអភិវឌ្ឍន៍ ដែលអាចជឿទុកចិត្តបាន សំដៅលើការបម្រើប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរឡើង។[42] ដូចច្នេះ ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាក្នុងការអនុវត្តការងាររដ្ឋបាល គឺពិតជាមានសារៈសំខាន់ណាស់ ពីព្រោះវាមិនត្រឹមតែមានផលប្រយោជន៍ច្រើននោះទេ ថែមទាំងសបញ្ជាក់ឱ្យឃើញពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការធ្វើនុវានុវត្តន៍[43] ទៅលើការគ្រប់គ្រង និងបង្ហាញពីកម្រិតកើនឡើងនៃធនធានមនុស្សនៅកម្ពុជាទៀតផង។

**ជ. ពង្រឹងការគោរពច្បាប់**

ការចុះបញ្ជីក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសកាលពីមុន គឺជាសេវាសាធារណៈមួយដែលមន្ត្រីខិលខូចមួយចំនួនបានយកមករកស៊ីក្រៅផ្លូវការ ដែលជាហេតុបណ្តាលឱ្យមានអំពើពុករលួយកើតឡើងក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋ។ ម្យ៉ាងវិញទៀត ក្រុមហ៊ុនឯកជនមួយចំនួនបានឃុបឃិតជាមួយមន្ត្រីពុករលួយទាំងអស់នោះ ដើម្បីទទួលបានវិញ្ញាបនបត្រអាជីវកម្មមួយដែលមិនស្របច្បាប់ (ក្លែងក្លាយ) ដើម្បីយកទៅធ្វើអាជីវកម្មរបស់ពួកគេ។

ប៉ុន្តែនាពេលនេះតទៅ ការចុះបញ្ជីក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស គឺគេធ្វើដោយប្រព័ន្ធស្វ័យប្រវត្តិកម្ម ដែលជនខិលខូចមួយចំនួនមិនអាចយកសេវាមួយនេះទៅរកស៊ីខុសច្បាប់បានទៀតនោះទេ។ ទំនើបកម្មនេះបានធ្វើឱ្យមានការកាត់បន្ថយអំពើពុករលួយជាប្រព័ន្ធ និងធ្វើឱ្យអាជីវករ សហគ្រិន រួមទាំងមន្ត្រីផ្តល់សេវា រួមគ្នាគោរពច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលបានដាក់ឱ្យអនុវត្តជាធរមាន។

---

[42] រាជរដ្ឋាភិបាលកម្ពុជា ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល គោលនយោបាយស្តីពី ការផ្តល់សេវាសាធារណៈ អនុម័តដោយគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៦

[43] នុវានុវត្តន៍(Innovation) គឺជារបស់ថ្មី គំនិតថ្មី មធ្យោបាយថ្មី នៅក្នុងការធ្វើអ្វីមួយឱ្យមានភាពប្រសើរឡើងជាងមុន (ដកស្រង់ចេញពី វចនានុក្រមអនឡាញ៖ Oxford Advanced Dictionary)

**ឈ. ការប្រមូលថវិកាជូនរដ្ឋមានសុក្រឹត្យភាព**

ទំនើបកម្មនៃសេវាមួយនេះរបស់ក្រសួងសាធារណការ និងដឹកជញ្ជូនធ្វើឱ្យមានការបង់ថ្លៃសេវាមានសុក្រឹត្យភាព ពីព្រោះអ្នកស្នើសុំសេវាត្រូវបង់ថ្លៃតាមចំនួនកំណត់តាមប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសាធារណៈការ និងដឹកជញ្ជូន ដែលការបង់ថ្លៃនេះធ្វើឡើងតាមរយៈប្រព័ន្ធស្វ័យប្រវត្តិកម្ម(ប្រព័ន្ធអនឡាញ)។ នេះជាហេតុដែល ទិន្នន័យនៃចំនួនថវិកាទាំងមូលមានភាពច្បាស់លាស់ លែងមានអំពើពុករលួយនៃការបង់ថ្លៃសេវា(ចំណាយក្រោមតុ)។

ដូចនេះ ថវិកាដែលប្រមូលបានទាំងអស់ គឺបង់ជូនរដ្ឋទាំងស្រុងលែងមានការបាត់ចំនួននៃទិន្នន័យទឹកប្រាក់ដែលប្រមូលដូចមុនទៀតហើយ។

## ៣.២ ចំណុចខ្សោយ

ទន្ទឹមនឹងគុណសម្បត្តិ ក៏មានគុណវិបត្តិមួយចំនួនដែលកើតឡើងនៅក្នុងការអនុវត្តការចុះបញ្ជីក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសតាមប្រព័ន្ធស្វ័យប្រវត្តិកម្មនេះផងដែរ ពីព្រោះប្រព័ន្ធនេះទើបតែបានដាក់ឱ្យអនុវត្តនាចុងឆ្នាំ២០១៧ នេះប៉ុណ្ណោះ។ គុណវិបត្តិទាំងនោះមានដូចខាងក្រោមនេះ៖

**ក. ការអនុវត្តផ្ទាល់លើប្រព័ន្ធស្វ័យប្រវត្តិកម្ម (Online)**

ត្រូវពឹងផ្អែកទាំងស្រុងលើសេវាអ៊ិនធឺណេត ហើយជានិច្ចកាលសេវាអ៊ិនធឺណេត គឺតែងតែមានភាពយឺតយ៉ាវពេលខ្លះដាច់ទាំងស្រុង ឬគេហទំព័រមិនដំណើរការជាដើម។ ពេលខ្លះ អ្នកសុំសេវាបង់លុយមិនចូលក៏មាន។ ប្រព័ន្ធថ្មីនេះ បានតម្រូវឱ្យអ្នកស្នើសុំត្រូវប្រើប្រាស់បច្ចេកវិទ្យាពតិមានវិទ្យាដើម្បីចុះបញ្ជីធ្វើអាជីវកម្មដោយឆ្លងកាត់នីតិវិធីស្មុគស្មាញខ្លះៗ ហើយការយល់ដឹងរបស់ប្រជាពលរដ្ឋវិញទៀតសោតហាក់នៅមានកម្រិត ដែលវាជាបញ្ហាលំបាកមួយក្នុងការបំពេញបែបបទនានាតាមប្រព័ន្ធនេះ។

**ខ. ផលវិបាកនៃការធ្វើកំណែទម្រង់**

ការផ្លាស់ប្តូរការចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោក នាំឱ្យមានការកំណែទម្រង់ពីរ គឺកំណែទម្រង់ឯកសារ និងកំណែទម្រង់បរិបទការងារ។ ពេលប្រើប្រាស់ប្រព័ន្ធចាស់ ការបំពេញបែបបទទាំងអស់ត្រូវធ្វើឡើងជាក្រដាសស្នាម ហើយត្រូវយកទៅដាក់ជូននៅទីតាំងផ្តល់សេវាដែលកំណត់ដោយក្រសួងសាធារណការ និងដឹកជញ្ជូន។ តែចំពោះប្រព័ន្ធថ្មីនេះវិញ ឯកសារទាំងអស់តម្រូវឱ្យធ្វើជាពីរទម្រង់ គឺទម្រង់លិខិតស្នាម និងទម្រង់អេឡិចត្រូនិច។ ឯកសារ និងទិន្នន័យដែលបានធ្វើជាអេឡិចត្រូនិចត្រូវបញ្ជូនទៅមន្ត្រីដែលទទួលបន្ទុកតាមរយៈប្រព័ន្ធស្វ័យប្រវត្តិកម្ម។ ទោះជាយ៉ាងណាក៏ដោយ ឯកសារអេឡិចត្រូនិចនាពេលបច្ចុប្បន្ននេះ គឺមិនទាន់មានការទទួលស្គាល់ពីអានុភាពគតិ

យុត្តនៅឡើយទេ ជាហេតុតម្រូវឱ្យអ្នកស្នើសុំត្រូវយកឯកសារជាលិខិតស្នាមទៅជួបផ្ទាល់ជាមួយមន្ត្រីផ្តល់សេវានៅទីតាំងផ្តល់សេវាម្តងទៀត ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវ។

មួយវិញទៀត ថ្វីត្បិតប្រព័ន្ធនេះទើបតែដាក់ឱ្យប្រើប្រាស់ក្តី(កំពុងសាកល្បង) ក៏ទាមទារឱ្យមានការផ្លាស់ប្តូរបរិបទការងាររបស់មន្ត្រីបម្រើកិច្ចការផងដែរ។ ជាក់ស្តែង ប្រព័ន្ធចាស់ គឺប្រើប្រាស់លិខិតស្នាម និងបំពេញដោយដៃ តែប្រព័ន្ធថ្មីប្រើប្រាស់បច្ចេកវិទ្យាមកជំនួសវិញ ដូច្នេះហើយតម្រូវឱ្យមន្ត្រីដែលកំពុងបម្រើការត្រូវតែចេះប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា។ បន្ថែមពីនេះទៀត រចនាសម្ព័ន្ធថ្មីនៃមន្ត្រីធ្វើការត្រូវមានការកែប្រែ ហើយសម្ភារៈការិយាល័យវិញទៀតសោត ត្រូវតែមានគ្រប់ទៅតាមតម្រូវការនៃទំនើបភាវូបនីយកម្មដែលជាបុព្វហេតុត្រូវចំណាយថវិកាច្រើន។

**គ. ការយល់ដឹងរបស់មន្ត្រីផ្តល់សេវាទាក់ទងនឹងប្រព័ន្ធថ្មី**

សេវាសាធារណៈ ស្តីអំពីការចុះបញ្ជីក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសតាមប្រព័ន្ធស្វ័យប្រវត្តិកម្មនេះ ទាមទារឱ្យមន្ត្រីផ្តល់សេវានេះមានចំណេះដឹងច្បាស់លាស់ពីប្រព័ន្ធនេះ ប៉ុន្តែចំពោះការយល់ដឹងរបស់មន្ត្រីផ្តល់សេវាដែលទាក់ទងនឹងប្រព័ន្ធនេះនៅមានកម្រិតនៅឡើយ។ ការដាក់ឱ្យអនុវត្តនូវប្រព័ន្ធថ្មីនេះធ្វើឱ្យមន្ត្រីមួយចំនួនតាមមិនទាន់ និងមានភាពស្មុគស្មាញពីនីតិវិធីថ្មីដែលទាមទារឱ្យមានការបណ្តុះបណ្តាលពួកគាត់ជាចាំបាច់។

ផលវិបាកបែបនេះហើយ បានធ្វើឱ្យក្រសួងសាធារណការ និងដឹកជញ្ជូនចំណាយថវិកាយ៉ាងច្រើនក្នុងការជួលក្រុមហ៊ុនឯកជន និងអ្នកជំនាញការបរទេស មកធ្វើការបណ្តុះបណ្តាលមន្ត្រីរបស់ខ្លួនជាបន្តបន្ទាប់ ដើម្បីពង្រឹងសមត្ថភាពរបស់មន្ត្រីឱ្យអនុវត្តការងារប្រកបដោយប្រសិទ្ធភាពជូនប្រជាពលរដ្ឋ។

## ៣.៣ បញ្ហាប្រឈម

កន្លងមកនៅក្រសួងសាធារណការ និងដឹកជញ្ជូន មិនមែនមានតែប្រព័ន្ធស្វ័យប្រវត្តិកម្មសម្រាប់ការចុះបញ្ជីអាជីវកម្មដឹកជញ្ជូនផ្លូវគោកតែមួយមុខនោះទេ តែមានការចុះបញ្ជីយានជំនិះ ការត្រួតពិនិត្យលក្ខណៈបច្ចេកទេស និងការផ្តល់បណ្ណបើកបរជាដើម។

ការបង្កើត និងគ្រប់គ្រងប្រព័ន្ធស្វ័យប្រវត្តិកម្មនេះផងដែរ ប្រទេសកម្ពុជានៅមិនទាន់មានលទ្ធភាពគ្រប់គ្រាន់ទាំងស្រុងក្នុងការគ្រប់គ្រងនៅឡើយ ដោយត្រូវអាស្រ័យលើការជួយជ្រោមជ្រែង និងជំនួយឧបត្ថម្ភពីអង្គការ ឬពីសំណាក់ក្រុមហ៊ុនឯកជន។ បញ្ហាប្រឈមមួយចំនួនដូចជា កង្វះថវិកាសម្ភារៈបច្ចេកទេស អ្នកជំនាញ អាចនឹងកើតមានឡើងខ្លះ នៅពេលធ្វើនុវានុវត្តន៍បន្ថែមលើប្រព័ន្ធនេះក្នុងករណីដែលអង្គការ ក៏ដូចជាក្រុមហ៊ុនទាំងនោះលែងផ្តល់ជំនួយ។បើពិនិត្យបន្ថែមពីនេះទៅទៀត នាពេលបច្ចុប្បន្ននេះ ការបំពេញសេវាសាធារណៈរបស់រដ្ឋ ជាពិសេស សេវាដែលមានភ្ជាប់

ជាមួយនឹងប្រព័ន្ធតិចណូឡូជី ជាកម្រងសេវាដែលមានការលំបាកទាំងអ្នកផ្តល់សេវា និងអ្នកទទួលសេវា។ យើងអាចនិយាយបានថា ចំណេះដឹងផ្នែកពតិមានវិទ្យារបស់ប្រជាពលរដ្ឋខ្មែរនៅមានកម្រិត ដែលជាកត្តាមួយធ្វើឱ្យមានផលលំបាកជាបន្តបន្ទាប់ចំពោះដំណើរនៃការបំពេញសេវាទាំងអស់នោះ។

ដូចគ្នានេះផងដែរ ការចុះបញ្ជីក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសតាមប្រព័ន្ធស្វ័យប្រវត្តិកម្មនេះ គឺក្រសួងទើបតែបានដាក់ឱ្យអនុវត្តនាចុងឆ្នាំ២០១៧ ដែលវាជាដំណាក់កាលពាក់កណ្តាលស្វ័យប្រវត្តិកម្ម (កំពុងសាកល្បង) ហេតុដូចនេះ គេនៅបន្តឃើញមានអ្នកទទួលយកសេវានេះមានការត្អូញត្អែរពីនីតិវិធីខ្លះៗ ហើយមានអ្នកស្នើសុំខ្លះនៅតែពឹងមន្ត្រីជំនាញនៅទីនោះឱ្យជួយសម្រួលជំនួសខ្លួនដដែល។ ទង្វើបែបនេះជារឿយៗ បានធ្វើឱ្យមន្ត្រីមួយចំនួនតូចនៅតែអាចឆ្លៀតឱកាសទាញយកផលប្រយោជន៍ពីសេវានេះទោះតិច ឬច្រើនក្តី ហើយនេះជាហេតុដែលអំពើពុករលួយនៅតែបន្តកើតមានឡើងនៅក្នុងប្រព័ន្ធរដ្ឋបាលខ្មែរ។ មិនត្រឹមតែប៉ុណ្ណោះ វាបាននឹងកំពុងធ្វើឱ្យបាត់បង់នូវតម្លាភាពនៃការផ្តល់សេវាសាធារណៈផងដែរ។

លើសពីនេះទៀត យើងបានរកឃើញផងដែរ ក្រោយពីប្រកាស៣៥៤ ប្រក.សក បានដាក់ឱ្យអនុវត្ត ហើយចំពោះក្រុមហ៊ុនអាជីវកម្មមួយចំនួនដែលបានចុះបញ្ជីរួចហាក់ដូចជាមិនសូវយល់ដឹងពីកាតព្វកិច្ចនានា បន្ទាប់ពីទទួលបានវិញ្ញាបនបត្រចុះបញ្ជី។ បើពិនិត្យមើលឱ្យច្បាស់លាស់ទៅ ក្រុមហ៊ុនទាំងនោះហាក់ដូចជាចង់គេចវេសពីច្បាប់ដែលមានចែងជាធរមាន ជាក់ស្តែង គឺរបាយការណ៍អំពីទិន្នផលដឹកជញ្ជូនរបស់ក្រុមហ៊ុនដែលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោក ដែលត្រូវធ្វើជាប្រចាំខែ ហើយត្រូវផ្ញើជូនក្រសួងសាធារណការ និងដឹកជញ្ជូន។

មួយវិញទៀត ដោយសារសេវាចុះបញ្ជីក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសនេះស្ថិតនៅក្នុងដំណាក់កាលពាក់កណ្តាលស្វ័យប្រវត្តិកម្ម (កំពុងសាកល្បង) បែបនេះហើយ ទៅថ្ងៃអនាគតវាអាចប្រឈមនឹងការបិទចោលលែងឱ្យអនុវត្តន៍តទៅទៀត ក្នុងករណីដែលប្រព័ន្ធនេះមិនបានធ្វើទំនើបកម្ម ឬនៅតែបន្តមានភាពរអាក់រអួលក្នុងការប្រតិបត្តិការសេវានេះ។

### ៣.៤ ដំណោះស្រាយ

ដើម្បីឆ្លើយតបទៅនឹងចំនុចខ្សោយ និងបញ្ហាប្រឈមដែលកំពុងកើតមានចំពោះការចុះបញ្ជីក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ក្រសួងសាធារណៈការ និងដឹកជញ្ជូន ក៏ដូចជាដៃគូពាក់ព័ន្ធបាននឹងកំពុងយកចិត្តទុកដាក់ចំពោះបញ្ហាទាំងនោះដូចខាងក្រោមនេះ៖

- អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោកមានកាតព្វកិច្ច ត្រូវគ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងណែនាំអនុវត្តក្នុងការផ្តល់វិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសនៅក្នុង

ព្រះរាជាណាចក្រកម្ពុជា។[44]

- ក្រសួងសាធារណការ និងដឹកជញ្ជូនបានបង្កើតក្រុមការងារជំនាញដាច់ដោយឡែកមួយ ដើម្បីទទួលបន្ទុកក្នុងការតម្លើងប្រព័ន្ធស្វ័យប្រវត្តិកម្ម និងទទួលខុសត្រូវដោះស្រាយភ្លាមៗចំពោះបញ្ហាដែលកើតមានឡើងនៅក្នុងប្រតិបត្តិការផ្តល់សេវាជូនប្រជាពលរដ្ឋដូចជា ការរអាក់រអួលរបស់វេបសាយ ការបង់លុយមិនចូលប្រព័ន្ធ ឬការឡុកអ៊ិន(Log In) មិនចូលជាដើម។ ក្រុមការងារជំនាញនេះគឺមានសមាសភាពមកពី នាយកដ្ឋានដឹកជញ្ជូនផ្លូវគោក នាយកដ្ឋានពត៌មានវិទ្យា និងទំនាក់ទំនងសាធារណៈ និងមកពីក្រុមហ៊ុន ខេម អ៊ិនហ្វូសឺវីស (ក្រុមហ៊ុននៅកម្ពុជា)។[45]

- ម្យ៉ាងវិញទៀត ក្រសួងសាធារណការ និងដឹកជញ្ជូនក៏មានផងដែរនូវ សមាគមដឹកជញ្ជូនទំនិញផ្លូវគោកកម្ពុជា និងសមាគមដឹកអ្នកដំណើរកម្ពុជា។ រាល់ក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនទំនិញ និងអ្នកដំណើរតាមផ្លូវគោកទាំងអស់ដែលបានចូលជាសមាជិកត្រូវបង់វិភាគទានជាប្រចាំដល់សមាគមតាមលក្ខន្តិកៈដែលមានចែង។ សមាគមទាំងពីរនេះបង្កើតឡើងដោយក្រសួងសាធារណការ និងដឹកជញ្ជូន និងចុះបញ្ជីនៅក្រសួងមហាផ្ទៃ ដែលតំណាងឱ្យដៃគូអាជីវកម្មទាំងអស់ និងរាជរដ្ឋាភិបាលកម្ពុជា ហើយសមាគមទាំងពីរនេះដើរតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រងក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកទាំងអស់ដែលបានចូលជាសមាជិក។ សមាគមទាំងអស់នេះ ជាអ្នកដោះស្រាយរាល់បញ្ហានានាដែលកើតមានឡើង និងជាអ្នកផ្សព្វផ្សាយពន្យល់ឱ្យបានដឹងពីច្បាប់ ឬបទដ្ឋានគតិយុត្តផ្សេងៗដែលអាជ្ញាធរបានដាក់ចេញ។[46]

- ក្រសួងបានបន្តពង្រឹងការបណ្តុះបណ្តាលមន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឱ្យចេះប្រើប្រព័ន្ធស្វ័យប្រវត្តិកម្មឱ្យបានគ្រប់ៗគ្នា។[47] មិនត្រឹមតែប៉ុណ្ណោះ ក្រសួងបានជំរុញឱ្យមានការចុះធ្វើកម្មសិក្សាក្រៅប្រទេស ដើម្បីដកស្រង់បទពិសោធន៍ថ្មីៗពីប្រព័ន្ធស្វ័យប្រវត្តិកម្មនេះ។

- ក្រសួងបានបន្តសហការជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ក្នុងការចុះបញ្ជីឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ ងាយស្រួល មានតម្លាភាព និងមានគណនេយ្យភាព។[48]

---

[44] ប្រកាសលេខ ៣៩៤ ប្រក.សក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៧ ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការចេញលិខិតអនុញ្ញាតឱ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស,ប្រការ១២,បញ្ជីឧបសម្ព័ន្ធទី ២

[45] យោងតាមការសាកសួរផ្ទាល់ជាមួយអនុប្រធាននាយកដ្ឋានពត៌មានវិទ្យា និងទំនាក់ទំនងសាធារណៈ

[46] យោងតាមការសាកសួរផ្ទាល់ជាក់ស្តែងជាមួយប្រធានការិយាល័យអាជីវកម្មដឹកជញ្ជូនក្នុងប្រទេស និងឆ្លងដែនតាមផ្លូវគោក

[47] របាយការណ៍ស្តីពីលទ្ធផលការងាររបស់អគ្គនាយកដ្ឋានផ្លូវគោកប្រចាំឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨, ទំព័រ៨

[48] របាយការណ៍ស្តីពីលទ្ធផលការងាររបស់អគ្គនាយកដ្ឋានផ្លូវគោកប្រចាំឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨, ទំព័រ៩

## ៣.៥ កាលានុវត្តភាព

ប្រសិនបើការធ្វើនុវានុវត្តន៍ស្វ័យប្រវត្តិកម្មឱ្យមានភាពងាយស្រួលជាងនេះ វានឹងឈានដល់ដំណាក់កាលមួយជាប្រព័ន្ធស្វ័យប្រវត្តិកម្មពេញលេញ និងមានលក្ខណៈស្តង់ដារ នោះវានឹងផ្តល់កាលានុវត្តភាពជាច្រើនដល់ប្រជាពលរដ្ឋជាម្ចាស់អាជីវកម្ម និងសេដ្ឋកិច្ចជាតិដូចជា៖

- ការគាំពារតាមផ្លូវច្បាប់ ៖ ដោយហេតុថា វាមានភាពងាយស្រួលឆាប់រហ័ស ក្នុងការបំពេញនីតិវិធីមិនយឺតយ៉ាវដូចមុន និងអស់ថ្លៃសេវាតិច ធ្វើឱ្យក្រុមហ៊ុនទាំងនោះនឹងមិនមានការគេចវេសពីការចុះបញ្ជីធ្វើអាជីវកម្មទៀតនោះឡើយ។ ក្រុមហ៊ុននីមួយៗត្រូវតែយកចិត្តទុកដាក់ក្នុងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាឱ្យបានខ្ជាប់ខ្ជួន។ ការចុះបញ្ជីធ្វើអាជីវកម្មនាំឱ្យម្ចាស់អាជីវកម្មទទួលបានការគាំពារពីផ្លូវច្បាប់ ដោយមិនចាំបាច់ត្រូវរងការផាកពិន័យពីសំណាក់ភាគីមានសមត្ថកិច្ចក្នុងការប្រកបអាជីវកម្មដឹកជញ្ជូនដោយគ្មានការអនុញ្ញាតទៀតទេ។

- សិទ្ធិចូលទីផ្សារធំៗ ៖ អាចទទួលបានអតិថិជនច្រើន បង្កើនភាពជាដៃគូជាមួយក្រុមហ៊ុនដទៃ និងបន្ថែមសក្តានុពលនៃអាជីវកម្មតាមរយៈការពង្រីកសាខា ហើយប្រសិនបើចង់លក់ក្រុមហ៊ុន នោះក្រុមហ៊ុនដែលចុះបញ្ជីរួចអាចមានតម្លៃថ្លៃផងដែរ។

- ក្រុមហ៊ុនដឹកជញ្ជូនបរទេសមានទំនុកចិត្ត ៖ ដោយសារតែ ការអនុវត្តនូវការចុះបញ្ជីតាមប្រព័ន្ធស្វ័យប្រវត្តិកម្មនេះ គឺអាចទាក់ទាញក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោករបស់បរទេសមកបណ្តាក់ទុននៅកម្ពុជា ពីព្រោះក្រុមហ៊ុនទាំងអស់នោះមានភាពជឿជាក់ខ្ពស់ចំពោះប្រព័ន្ធច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា។

- ចំពោះសេដ្ឋកិច្ចជាតិ កាលណាក្រុមហ៊ុនបើកច្រើន នោះរដ្ឋអាចប្រមូលចំណូលបានរឹតតែច្រើនពីថ្លៃសេវាចុះបញ្ជីអាជីវកម្ម។ អាជីវកម្មដឹកជញ្ជូនផ្លូវគោកមិនថានៅក្នុងប្រទេស ឬឆ្លងដែនទេសុទ្ធសឹងតែជាធាតុផ្សំមិនអាចខ្វះបានក្នុងការធ្វើពាណិជ្ជកម្ម មានន័យថាកម្ពុជារឹតតែមានភាពរឹងមាំក្នុងការប្រកួតប្រជែងទំនិញ សេវាកម្មទាំងទីផ្សារក្នុងតំបន់ និងពិភពលោក ជាពិសេសគឺអាចទាក់ទាញវិនិយោគិនឱ្យមកវិនិយោគថែមទៀតផង ដោយសារតែវិស័យដឹកជញ្ជូនរបស់យើងមានភាពរីកចម្រើន។ ចំណុចនេះនឹងរួមចំណែកធ្វើឱ្យកម្រិតជីវភាពរបស់ប្រជាពលរដ្ឋមានភាពប្រសើរឡើង រីឯខឿនសេដ្ឋកិច្ចជាតិក៏កើនឡើងតាមនោះដែរ។

- អាចជាគំរូដល់ក្រសួងស្ថាប័នដទៃក្នុងការអនុវត្តតាម ៖ ក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋតាមរយៈប្រព័ន្ធស្វ័យប្រវត្តិកម្មរបស់ក្រសួងសាធារណការ និងដឹកជញ្ជូនបានទទួលការគាំទ្រពីប្រជាពលរដ្ឋយ៉ាងច្រើនកុះករផងដែរ។ សកម្មភាពបែបនេះហើយដែលជាគំរូមួយសម្រាប់ក្រសួង-ស្ថាប័ន

ដទៃៗទៀតយកជាគំរូតាម ក្នុងការអនុវត្តការផ្តល់សេវាសាធារណៈរបស់ស្ថាប័នខ្លួនជូនដល់ប្រជាពលរដ្ឋឱ្យបានកាន់តែប្រសើរឡើង។

- អាចឈានដល់ដំណាក់កាលនៃការអនុវត្តគោលការណ៍ E-Government ( រដ្ឋាភិបាលអេឡិចត្រូនិច ) ៖ គោលការណ៍នេះ រាជរដ្ឋាភិបាលកម្ពុជានាពេលបច្ចុប្បន្ន បាននឹងកំពុងតែយកចិត្តទុកដាក់យ៉ាងខ្លាំង ដើម្បីសម្រេចឱ្យបានការគ្រប់គ្រងកិច្ចការងាររដ្ឋបាសាធារណៈតាមរយៈប្រព័ន្ធអេឡិចត្រូនិច។ គោលការណ៍នេះ គឺជាអ្វីដែលប្រជាពលរដ្ឋគ្រប់រូបទន្ទឹងចង់បាន។ ដូចនេះ ការអនុវត្តការផ្តល់សេវាសាធារណៈរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ជាទំនើបកម្មថ្មីមួយ និងជាគន្លឹះដ៏សំខាន់ដើម្បីឈានទៅដល់ការអនុវត្តគោលការណ៍ E-Government ។

# សេចក្តីសន្និដ្ឋាន

សព្វថ្ងៃនេះ យើងសង្កេតឃើញថាបច្ចេកវិទ្យា គឺមានការរីកចម្រើនគួរឱ្យកត់សម្គាល់។ ការរីកចម្រើននៃបច្ចេកវិទ្យា គឺបានជួយសម្រួលដល់ជីវភាពរស់នៅរបស់មនុស្ស មិនថានៅក្នុងការបំពេញការងារ ការសិក្សា ការធ្វើអាជីវកម្ម ពាណិជ្ជកម្មផ្សេងៗ គឺសុទ្ធតែពឹងផ្អែកទៅលើប្រព័ន្ធបច្ចេកវិទ្យាទំនើបៗ។ កាលពីចុងឆ្នាំ ២០១៧ ក្រសួងសាធារណការ និងដឹកជញ្ជូន ក៏បានចេញនូវប្រកាសស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការចេញលិខិតអនុញ្ញាតឱ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស ដោយនីតិវិធីនៃការស្នើសុំវិញ្ញាបនបត្រចុះបញ្ជីអាជីវកម្មដឹកជញ្ជូនផ្លូវគោកនេះ គឺត្រូវធ្វើឡើងតាមរយៈប្រព័ន្ធស្វ័យប្រវត្តិកម្ម។ យើងដឹងហើយថា ប្រព័ន្ធស្វ័យប្រវត្តិកម្ម គឺសំដៅទៅលើការរួមបញ្ចូលគ្នានៃកម្មវិធី និងឯកសារទាំងអស់ ហើយត្រូវបានដំណើរការដោយស្វ័យប្រវត្តិ ដោយមិនត្រូវការមនុស្សដើម្បីផ្តល់ពត៌មាន ឬធ្វើការណែនាំសម្រាប់ប្រតិបត្តិការនីមួយៗឡើយ។

ចំពោះចំណុចខ្លឹមនៃប្រធានបទសារណានេះវិញ គឺយើងសង្កត់ធ្ងន់ទៅតែលើនីតិវិធីនៃការចុះបញ្ជីក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ដោយនីតិវិធីនៃការស្នើសុំសេវានេះត្រូវបានបែងចែកជាបីដំណាក់កាលធំៗដូចជា ដំណាក់កាលអ្នកដាក់ពាក្យសុំស្នើ ដំណាក់កាលមន្ត្រីផ្តល់សេវា និងដំណាក់កាលរវាងមន្ត្រីផ្តល់សេវា និងអ្នកដាក់ពាក្យសុំស្នើ។ រាល់នូវដំណាក់កាលនីមួយៗ ត្រូវបានបែងចែកជាចំណុចតូចៗមួយចំនួនបន្តទៀត ដែលរៀបរាប់លំអិតពីនីតិវិធីនីមួយៗតាមលំដាប់លំដោយ។ យើងបានជ្រាបច្បាស់ពីចំណុចទាំងនោះមកហើយតាមរយៈខ្លឹមសារនៃអត្ថបទសារណានេះ យើងអាចនិយាយបានថា នីតិវិធីនៃការចុះបញ្ជីក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម គឺមិនសូវមានភាពសាំញ៉ាំ និងផលវិបាកច្រើនណាស់ណាដល់អ្នកស្នើសុំឡើយ ដោយសារការចុះបញ្ជីតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម គឺផ្តល់ភាពងាយស្រួលដល់បងប្អូនប្រជាពលរដ្ឋ ដែលមានបំណងចង់បើកក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស។

បន្ថែមពីនេះទៀត ក្រុមហ៊ុនអាជីវកម្មក៏ត្រូវមានទំនួលខុសត្រូវផងដែរ ក្រោយពីទទួលបានវិញ្ញាបនបត្រចុះបញ្ជីអាជីវកម្មដឹកជញ្ជូនផ្លូវគោករួចមក គឺនៅមានកាតព្វកិច្ចមួយចំនួនដែលក្រសួងសាធារណការ និងដឹកជញ្ជូនតម្រូវឱ្យអនុវត្តន៍ត។ ក្នុងករណីដែលក្រុមហ៊ុនអាជីវកម្មមិនគោរព និងប្រតិបត្តិតាមការកំណត់របស់ក្រសួងនោះ វិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសអាចអស់សុពលភាពដោយស្វ័យប្រវត្តិ គឺផ្អែកលើកំហុសជាក់ស្តែងដែលបានកើតឡើង។

ថ្វីបើការដាក់ឱ្យអនុវត្តនូវប្រព័ន្ធស្វ័យប្រវត្តិកម្ម ទើបតែបានរយៈពេលខ្លីមែនពិត ប៉ុន្តែយើងអាចដឹងថា ការអនុវត្តប្រព័ន្ធស្វ័យប្រវត្តិកម្មនេះ បាននាំយកមកនូវផលវិជ្ជមានជាច្រើនដល់រដ្ឋក៏ដូច

ជាក្រសួង-ស្ថាប័ន ដែលគុណសម្បត្តិទាំងនោះមានដូចជា ការកាត់បន្ថយចំណាយថវិការដ្ឋ ការកាត់បន្ថយការិយាធិបតេយ្យ ការកាត់បន្ថយថ្លៃធ្វើដំណើរ និងជំនួបរវាងមន្ត្រី និងអ្នកទទួលសេវា ការលុបបំបាត់ការប្រើប្រាស់វិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មក្លែងក្លាយ មានតម្លាភាពក្នុងការបង់ថ្លៃសេវា ការលុបបំបាត់ចំណាយក្រៅផ្លូវការ ការបង្ហាញពីកំណែទម្រង់លើការផ្តល់សេវាសាធារណៈ ការពង្រឹងការគោរពច្បាប់ និងការប្រមូលថវិកាជូនរដ្ឋមានសុក្រឹត្យភាព។ ទន្ទឹមនឹងផលវិជ្ជមាននេះផងដែរ ក៏មាននូវចំណុចអវិជ្ជមានមួយចំនួនតូច ដែលទាក់ទងទៅនឹងប្រព័ន្ធថ្មីនេះចំពោះមន្ត្រីផ្តល់សេវាដែលពួកគាត់ពុំទាន់យល់ច្បាស់ពីរបៀបប្រើប្រាស់ តែចំណុចនេះមិនចោទជាបញ្ហាធំនោះទេ ព្រោះមនុស្សក្នុងសង្គមយើងសម័យនេះ គឺមានការយល់ដឹងខ្ពស់អំពីបច្ចេកវិទ្យាទំនើប ដោយគ្រាន់តែត្រូវចំណាយពេលវេលាបន្តិចក្នុងការស្វែងយល់ពីវា។ ដោយឡែក ចំពោះបញ្ហាប្រឈមនានាដែលកើតមានឡើងនៅក្នុងការអនុវត្តនីតិវិធីនៃការចុះបញ្ជីក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្រសួងសាធារណការ និងដឹកជញ្ជូន រួមជាមួយដៃគូពាក់ព័ន្ធក៏កំពុងតែអនុវត្ត និងធ្វើការយ៉ាងសស្រាក់សស្រាំដើម្បីដោះស្រាយនូវបញ្ហាទាំងនោះ ទោះបីជាមានឧបសគ្គមួយចំនួនមករារាំងក៏ដោយ។

ជាចុងបញ្ចប់ កិច្ចការស្រាវជ្រាវនេះសបញ្ជាក់ឱ្យឃើញថា ការចុះបញ្ជីក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម គឺបានផ្តល់នូវផលប្រយោជន៍យ៉ាងច្រើនដល់សង្គម ទាំងផ្នែកច្បាប់ និងផ្នែកសេដ្ឋកិច្ច ឱ្យមានភាពប្រសើរឡើងនិងបង្កើនចំណូលជូនជាតិ ជាពិសេសទទួលបានការគាំទ្រពីសំណាក់ប្រជាពលរដ្ឋពីគ្រប់ទិសទី។ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថាថ្នាក់ដឹកនាំនឹងមានវិធានការពង្រឹង និងអភិវឌ្ឍន៍ជំនាញបច្ចេកទេសដោយបង្កើតនូវប្រព័ន្ធស្វ័យប្រវត្តិកម្មឱ្យបានច្រើនបន្ថែមទៀតលើគ្រប់វិស័យ ដើម្បីពន្លឿននូវប្រតិបត្តិការគ្រប់ប្រភេទនូវតាមបណ្តាក្រសួង-ស្ថាប័ន ក៏ដូចជាផ្តល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋទូទាំងប្រទេស ដែលជាហេតុជំរុញឱ្យប្រទេសជាតិទាំងមូលរីកចម្រើនលូតលាស់ប្រកបដោយ ចីរភាព និងវឌ្ឍនភាពជាតិ។

# អនុសាសន៍

យើងបានសិក្សាពីខាងលើរួចមកហើយ នូវផលវិបាក និងបញ្ហាប្រឈមដែលកំពុងកើតមានចំពោះនីតិវិធីនៃការចុះបញ្ជីក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស ហើយក្រសួងសាធារណការ និងដឹកជញ្ជូនបានដាក់ចេញនូវដំណោះស្រាយមួយចំនួនផងដែរ។ ក្នុងឱកាសនេះ យើងខ្ញុំសូមផ្តល់នូវអនុសាសន៍ខ្លះៗ ដើម្បីជាគំនិតពិចារណា និងកែលម្អឱ្យបានកាន់តែល្អប្រសើរឡើងដូចតទៅនេះ៖

**ក. ក្រសួងសាធារណការ និងដឹកជញ្ជូន**

- ក្រសួងគួរតែផ្ទេរមុខងារនេះទៅឱ្យមន្ទីរតាមបណ្តាខេត្ត-រាជធានី ៖ ប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ កំពុងតែអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ដែលសំដៅដល់ការលើកកំពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ យ៉ាងណាមិញ សេចក្តីសម្រេចលេខ ៣៩ សសរ របស់រាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការរៀបចំផ្ទេរមុខងារជាក់លាក់នានាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ បានសម្រេចឱ្យមានការរៀបចំផ្ទេរមុខងារចំនួន២៨ ពីក្រសួង-ស្ថាប័នក្នុងវិស័យអាទិភាពនានាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលក្រសួងសាធារណការ និងដឹកជញ្ជូន បានតម្រូវឱ្យផ្ទេរមុខងារ/កិច្ចការ ចំនួន៨ ទៅរដ្ឋបាលថ្នាក់ក្រោមជាតិ តែក្នុងចំណោមមុខងារទាំងអស់នោះ គេមិនឃើញមានមុខងារស្តីពី ការចុះបញ្ជីក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសនោះទេ។[49]

ដោយមើលឃើញពីកង្វះខាតនេះ ក្រសួងគួរផ្ទេរមុខងារនេះទៅឱ្យមន្ទីរតាមបណ្តាខេត្ត-រាជធានីជាអ្នកអនុវត្តម្តង ដោយហេតុថា នៅតាមបណ្តាខេត្តមានក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោកមួយចំនួន ដែលមិនមានទីតាំងស្ថិតនៅរាជធានីភ្នំពេញទេ ហើយបើការផ្ទេរមុខងារប្រព្រឹត្តទៅបានរលូន នោះការផ្តល់សេវាជូនប្រជាពលរដ្ឋនឹងកាន់តែនៅកៀកប្រជាពលរដ្ឋ និងអាចគ្រប់គ្រងអាជីវកម្មរបស់ពួកគេបានកាន់តែល្អប្រសើរជាងមុន។ ប៉ុន្តែ ក្រសួងត្រូវតែដាក់ចេញគោលការណ៍ និងបទដ្ឋានគតិយុត្តឱ្យបានច្បាស់លាស់ជាមុនសិន ហើយការបណ្តុះ បណ្តាលជំនាញមន្ត្រីលើប្រព័ន្ធប្រតិបត្តិការសេវានេះ គឺជាការងារអាទិភាពដែលក្រសួងត្រូវយកចិត្តទុកដាក់។

- ក្រសួងគួរតែបង្កើតក្រុមត្រួតពិនិត្យ និងតាមអង្កេតក្រុមហ៊ុនអាជីវកម្មទាំងនោះ៖ ក្រុមហ៊ុនមួយចំនួនតូច ក្រោយពីបានចុះបញ្ជីរួចមិនបានបំពេញកាតព្វកិច្ចតាមច្បាប់ដែលបានចែងនោះទេ ហើយមានក្រុមហ៊ុនខ្លះប្រព្រឹត្តខុសច្បាប់ទៀតផង ក្រសួងគួរតែចាត់វិធានការមួយថ្មី គឺការបង្កើត

[49] សូមអានសេចក្តីសម្រេចលេខលេខ ៣៩ សសរ របស់រាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការរៀបចំផ្ទេរមុខងារជាក់លាក់នានាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

ក្រុមត្រួតពិនិត្យ និងតាមអង្កេតមួយ។ យើងបានដឹងហើយថា ក្រសួងទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជាយើងបានបង្កើតនាយកដ្ឋានប៉ូលីសទេសចរណ៍ ដែលមានតួនាទី ភារកិច្ចតាមដាន និងត្រួតពិនិត្យរាល់សេវា ឬអាជីវកម្មដែលផ្តល់អាជ្ញាបណ្ណដោយក្រសួងទេសចរណ៍។ ដូចនេះ បើអាចធ្វើទៅបាន ក្រសួងសាធារណការ និងដឹកជញ្ជូន គួរតែបង្កើតឱ្យមាននាយកដ្ឋានមួយដែរ គឺនាយកដ្ឋានប៉ូលីសសាធារណការ និងដឹកជញ្ជូន។ នាយកដ្ឋាននេះ នឹងដើរតួនាទីសំខាន់ក្នុងការគ្រប់គ្រងក្រុមហ៊ុនអាជីវកម្មទាំងអស់នោះ។

- ក្រសួងគួរតែធ្វើទំនើបកម្មបន្តទៀតទៅលើគេហទំព័រ transportlicense.mpwt.gov.kh ពីព្រោះវាស្ថិតនៅក្នុងដំណាក់កាលកំពុងសាកល្បងនៅឡើយ ហើយភាពរអាក់រអួលកំពុងតែកើតមានជាបន្តបន្ទាប់។

- ស្ថាប័នពាក់ព័ន្ធទាំងអស់គួរតែពង្រឹងការផ្សព្វផ្សាយពន្យល់បន្តទៀត ពីបទដ្ឋានគតិយុត្តនានាដែលដាក់ឱ្យអនុវត្តពាក់ព័ន្ធនឹងសេវាសាធារណៈមួយនេះ។

- ក្រសួង និងស្ថាប័នពាក់ព័ន្ធទាំងអស់គួរតែសហការជាមួយអង្គការ ក្រុមហ៊ុន ដៃគូអភិវឌ្ឍន៍ដូចជា JICA និងCMVIC ជាដើម។

- ក្រសួងគួរតែបណ្តុះបណ្តាលមន្ត្រីបំពេញសេវាឱ្យកាន់តែច្បាស់លាស់ និងស្ទាត់ជំនាញបន្ថែមទៀត។

- ក្រសួងគួរតែធ្វើការដាក់ពិន័យដល់ក្រុមហ៊ុនអាជីវកម្មណា ដែលមិនគោរពតាមលិខិតបទដ្ឋានគតិយុត្តដែលបានដាក់ឱ្យអនុវត្ត។

- ក្រសួងគួរតែធ្វើការលើកទឹកចិត្តដល់ក្រុមហ៊ុនអាជីវកម្មណា ដែលបានអនុវត្តត្រឹមត្រូវទៅតាមការកំណត់របស់ក្រសួងដូចជា ការផ្តល់នូវបណ្ណសរសើរ និងឧទ្ទេសនាមក្រុមហ៊ុនអាជីវកម្មនោះឱ្យទៅក្រុមហ៊ុនអាជីវកម្មដទៃទៀតយកធ្វើជាគំរូ។

**ខ. ក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនផ្លូវគោក**

- ក្រុមហ៊ុននីមួយៗគួរតែពិនិត្យ និងជ្រើសរើសអ្នកបើកបរយានយន្តឱ្យបានល្អិតល្អន់ជាមុនសិន។ ដោយយើងសង្កេតឃើញថា សព្វថ្ងៃនេះការកើនឡើងនៃចំនួនគ្រោះថ្នាក់ចរាចរណ៍ដែលបណ្តាលមកពីអ្នកបើកបរយានយន្តដឹកទំនិញ និងអ្នកដំណើរ ដែលមិនគោរពច្បាប់មានកម្រិតមួយខ្ពស់គួរឱ្យកត់សម្គាល់។ ហេតុដូចនេះ ក្រុមហ៊ុននីមួយៗត្រូវអនុវត្តតាមច្បាប់ចរាចរណ៍ផ្លូវគោកដែលបានប្រកាសដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥។

- ក្រុមហ៊ុននីមួយៗគួរតែគោរព និងអនុវត្តទៅតាមប្រកាសលេខ ៣៥៣ ប្រក សក ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការចេញលិខិតអនុញ្ញាតឱ្យយានយន្តធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស

ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៧ ដោយតម្រូវឱ្យក្រុមហ៊ុនសុំលិខិតអនុញ្ញាតឱ្យយានយន្តធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស។

- ក្រុមហ៊ុននីមួយៗគួរតែគោរព និងអនុវត្តតាមប្រកាសស្តីពីសញ្ញាសម្គាល់រថយន្តធ្វើអាជីវកម្មដឹកជញ្ជូន ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៤ ដោយតម្រូវឱ្យយានយន្តធ្វើអាជីវកម្មត្រូវមានសញ្ញាសម្គាល់ និងលក្ខណៈបច្ចេកទេសសញ្ញាសម្គាល់ សម្រាប់រថយន្តដែលធ្វើអាជីវកម្មដឹកជញ្ជូនអ្នកដំណើរ និងអាជីវកម្មដឹកជញ្ជូនទំនិញ ដូចមានបង្ហាញក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។[50]

- ក្រុមហ៊ុននីមួយៗគួរតែគោរព និងអនុវត្តតាមប្រកាសលេខ ០៤៥ សក ស្តីពីការត្រួតពិនិត្យលក្ខណៈបច្ចេកទេសគ្រប់ប្រភេទ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៧ ដោយមានគោលបំណងធានាឱ្យយានជំនិះគ្រប់ប្រភេទមានសុវត្ថិភាពសម្រាប់ធ្វើចរាចរណ៍ ដើម្បីរួមចំណែកការពារបរិស្ថាន សុខភាព អាយុជីវិតមនុស្ស ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងបង្ការជៀសវាងនូវផលប៉ះពាល់ផ្សេងៗដែលបង្កឡើងពីយានជំនិះនៅក្នុងព្រះរាជាណាចក្រកម្ពុជា។[51]

[50] សូមអានប្រកាសលេខ០៣៨ សក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៤ ស្តីពីសញ្ញាសម្គាល់រថយន្តធ្វើអាជីវកម្មដឹកជញ្ជូន

[51] សូមអានប្រកាសលេខ ០៤៥ សក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៧ ស្តីពីការត្រួតពិនិត្យលក្ខណៈបច្ចេកទេសគ្រប់ប្រភេទ

# ឯកសារយោង

# ឯកសារយោង

## ក.គោលនយោបាយ

- គោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ អនុម័តដោយគណៈរដ្ឋមន្រ្តីក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៦

## ខ.ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ប្រកាសឱ្យប្រើនៅថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ២០០៥
- ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ដែលបានអនុម័តកាលពីថ្ងៃទី ០៣ ខែឧសភា ឆ្នាំ១៩៩៥
- ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ប្រកាសឱ្យប្រើនៅថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០០២
- សេចក្តីសម្រេចលេខ ៣៩ សសរ របស់រាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការរៀបចំផ្ទេរមុខងារជាក់លាក់នានាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសលេខ ០៣៨ សក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៤ ស្តីពីសញ្ញាសម្គាល់រថយន្តធ្វើអាជីវកម្មដឹកជញ្ជូន
- ប្រកាសលេខ ៣៩៤ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៧ ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការចេញលិខិតអនុញ្ញាតឱ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស
- ប្រកាសលេខ ២១៣ ព.ណ ចបព .ប្រក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម
- ប្រកាសលេខ ០៣៧ ប្រក.សក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៤ ស្តីពីនីតិវិធីនៃការអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោក
- ប្រកាសរួមលេខ ០១០ សហវ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- ប្រកាសលេខ ២៣៩ សក.ប្រក ចុះថ្ងៃទី ១២ ខែកក្កដា ឆ្នាំ ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានដឹកជញ្ជូនផ្លូវគោក។
- ប្រកាសលេខ ៣៩៣ ប្រក.សក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៧ ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការចេញលិខិតអនុញ្ញាតឱ្យយានយន្តធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស

- ប្រកាសលេខ ០៤៥ សក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៧ ស្តីពីការត្រួតពិនិត្យលក្ខណៈបច្ចេកទេសគ្រប់ប្រភេទ

## គ. របាយការណ៍

- របាយការណ៍ស្តីពីលទ្ធផលការងាររបស់អគ្គនាយកដ្ឋានផ្លូវគោកប្រចាំឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨

## ឃ. លិខិតរដ្ឋបាល

- សន្ទរកថា **ឯកឧត្តម ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូនក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០១៧ និងទិសដៅការងារឆ្នាំ ២០១៨ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៨
- សេចក្តីជូនដំណឹងលេខ ៧៩២ សក.ដជគ ចុះថ្ងៃទី២៩ ខែវិច្ឆកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យដំណើរការប្រព័ន្ធស្វ័យប្រវត្តិកម្មអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស
- សេចក្តីណែនាំលេខ ១៣៧ សក.ដជគ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពី ការអនុវត្តប្រកាសលេខ ៣៨៣ ប្រក.សក និងប្រកាសលេច៣៨៤ ប្រក.សក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ ២០១៧
- សេចក្តីជូនដំណឹងលេខ ៥៩៩ ស.ភ.រ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការប្រឡងប្រជែងសិស្សមន្ត្រីជាន់ខ្ពស់ជំនាន់ទី១០

## ខ. គេហទំព័រ


- Ihttps://www.igi-global.com /dictionary/electronic-government-e-government/9385
- www.technopedia.com
- www.kohthmey.com
- http://www.propertyarea.asia/
- http://www.caminfoservices.com/
- http://blog.1001stores.net/articles-of-incorporation/
- http://bizdoctors.asia
- https: transportlicense.mpwt.gov.kh/#/
- http://www.caminfoservices.com/

# បញ្ជីឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

| | |
|---|---|
| **បញ្ជីឧបសម្ព័ន្ធទី ១៖** ឯកសារពាក់ព័ន្ធនឹងការចុះស្រាវជ្រាវឯកសារ | ១. ពាក្យសុំអនុញ្ញាតចុះស្រាវជ្រាវឯកសារ |
| | **២.** បញ្ជីរាយនាមនិស្សិតថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈឆ្នាំទី៤ ជំនាន់ទី១១ ក្រុមP4C2 ឆ្នាំសិក្សា២០១៧-២០១៨ ដែលត្រូវចុះស្រាវជ្រាវឯកសារនៅក្រសួងសាធារណការ និងដឹកជញ្ជូន |
| | **៣.** លិខិតលេខ ៥៤៣ ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៨ ស្តីពីសំណើសុំអនុញ្ញាតឱ្យនិស្សិតចំនួន ០២ រូបចុះស្រាវជ្រាវឯកសារ |
| | **៤.** កំណាត់បង្ហាញរឿង |
| | **៥.** លិខិតលេខ ១៨០៦ ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការអនុញ្ញាតឱ្យនិស្សិតឆ្នាំទី៤ ចំនួន ០២នាក់ មកពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ចុះធ្វើកម្មសិក្សាចាប់ពីថ្ងៃទី ១៦-៣១ ខែឧសភា ឆ្នាំ២០១៨ នៅនាយកដ្ឋានពត៌មានវិទ្យា និងទំនាក់ទំនងសាធារណៈ |
| | **៦.** កម្រងសំណួរពាក់ព័ន្ធនឹងប្រធានបទសារណា |
| **បញ្ជីឧបសម្ព័ន្ធទី ២៖** ឯកសារពាក់ព័ន្ធនឹងប្រធានបទសារណា | ១. ប្រកាសលេខ ៣៨៤ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៧ ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការចេញលិខិតអនុញ្ញាតឱ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស |
| | **២.** ប្រកាសលេខ ៣៨៣ ប្រក.សក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៧ ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការចេញលិខិតអនុញ្ញាតឱ្យយានយន្តធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស |
| | **៣.** ប្រកាសរួមលេខ ០១០ សហវ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងសាធារណៈការ និងដឹកជញ្ជូន |
| | **៤.** សេចក្តីជូនដំណឹងលេខ ៧៩២ សក.ដជគ ចុះថ្ងៃទី២៩ ខែវិច្ឆកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យដំណើរការប្រព័ន្ធស្វ័យប្រវត្តិកម្មអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស |
| | **៥.** សេចក្តីណែនាំលេខ ១៣៧ សក.ដជគ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីការអនុវត្តប្រកាសលេខ ៣៨៣ ប្រក.សក និងប្រកាសលេខ៣៨៤ |

| | |
|---|---|
| | ប្រក.សក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៧ |
| **បញ្ជីឧបសម្ព័ន្ធទី ៣៖**<br>គំរូក្រុមហ៊ុន | **១**. គំរូអត្តសញ្ញាណបណ្ណរបស់ម្ចាស់ក្រុមហ៊ុនជី អូ វីហ្គោ ឯ.ក |
| | **២**. គំរូវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន ជី អូ វីហ្គោ ឯ.ក |
| | **៣**. គំរូលក្ខន្តិកៈរបស់ក្រុមហ៊ុន ជី អូ វីហ្គោ ឯ.ក (មានតែក្របមុខ) |
| | **៤**. គំរូស្ថិតិរថយន្តដឹកអ្នកដំណើររបស់ក្រុមហ៊ុន ខេ អេស អូ |
| | **៥**. គំរូលិខិតបញ្ជាក់ទីតាំងចំណតរថយន្តរបស់ក្រុមហ៊ុន ជី អូ វីហ្គោឯ.ក |
| | **៦**. គំរូបណ្ណប៉ាតង់របស់ក្រុមហ៊ុន ជី អូ វីហ្គោ ឯ.ក |
| | **៧**. គំរូពាក្យសុំវិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសរបស់ក្រុមហ៊ុន ជី អូ វីហ្គោ ឯ.ក |
| | **៨**. គំរូវិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសរបស់ក្រុមហ៊ុន ជី អូ វីហ្គោ ឯ.ក |
| **បញ្ជីឧបសម្ព័ន្ធទី ៤៖**<br>គំរូគេហទំព័រ | ១. transportlicense.mpwt.gov.kh |

# បញ្ជីឧបសម្ព័ន្ធទី ២
# ឯកសារពាក់ព័ន្ធនឹងប្រធានបទសារណា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន

លេខៈ ៣៤៤ ប្រ.ក.សក

រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែ១១ ឆ្នាំ២០១៧

# ប្រកាស
# ស្តីពី
# លក្ខខណ្ឌ និងនីតិវិធីនៃការចេញលិខិតអនុញ្ញាតឲ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៤១៦/៣៦៨ចុះថ្ងៃទី០៤ខែមេសាឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៥/០០១ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសាធារណការនិងដឹកជញ្ជូន



មហាវិថីព្រះនរោត្តម, ភ្នំពេញ
ទូរស័ព្ទ-ទូរសារៈ (៨៥៥) ២៣ ៤២៧ ៨៦២

## សម្រេច

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងគ្រប់គ្រងក្រុមហ៊ុនដែលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២.-**

